LAW OFFICE OF
Stewart H. Lim & Associates
Car Accident, Child Support, Immigration, Divorce, Bankruptcy, Living Trust, Defense you in Court
Main Office
100 Oceangate Blvd., Suite 1200, Long Beach, CA 90802
(562) 590-7181 FREE CONSULTATION

ខ្មែរប៉ុស្តិ៍
Khmer Post

Today Pharmacy
Fast and Friendly Service
Today Pharmacy
FREE DELIVERY

KHMER BILINGUAL BIWEEKLY NEWSPAPER
VOLUME 02 ISSUE 08 February 01st - 15th 2008 ADVERTISING (562) 313-2129 WWW.THEKHMERPOST.COM



# វត្ត IRAP: ជម្លោះត្រូវបញ្ចប់ដោយការបោះឆ្នោត ឬប្តឹងផ្តល់

## ▶ក្រុមព្រះសង្ឃសុំបិណ្ឌបាត្រឱ្យបញ្ចប់បញ្ហា

*Long Beach*, **មាជ សុណ្ណារ៉ា**

●●●ក្រុមព្រះសង្ឃ៥អង្គ ដែលមានព្រះចៅអធិការវត្តដឹកនាំ បានពិគ្រោះក្នុងជំនុំសង្ឃថា ( តនៅទំព័រទី០៨ )

# រូបអង្គរវត្តត្រូវគេបោះពុម្ពនៅនឹងស្បែកជើង

*Long Beach*, **មាជ សុណ្ណារ៉ា**

●●●ខ្មែរប៉ុស្តិ៍បានទទួលព័ត៌មានដ៏គួរឱ្យអៀនខ្មាស់ និងឈឺចាប់បំផុត នៅពេលដែលឃើញរូបអង្គរវត្តដែលជាព្រលឹងជាតិខ្មែរ បេតិកភ័ណ្ឌជាតិជាទីសក្ការៈរបស់ខ្មែរ ត្រូវបានគេបោះពុម្ពនៅបាតស្បែកជើងសង្រែកលក់ពាសពេញនៅផ្សារបាវិតក្នុងខេត្តស្វាយរៀង ( តនៅទំព័រទី១០ )



# ជីវិតស្ត្រីអ្នកចំរៀងខ្មែរម្នាក់ រស់ក្នុងសុបិន្តសហរដ្ឋអាមេរិក



**ដោយ : រ៉ាតាថ**

កាលពីក្មេង ដារ៉ានី តែងតែជាប់ចិត្តនឹងបទចំរៀង ។ ប៉ុន្តែរស់នៅប្រទេសកម្ពុជា នាងបានដឹងហើយថា ក្តីស្រមៃរបស់នាង ដែលចង់ក្លាយជាអ្នកចំរៀងនោះ ប្រាកដជាត្រូវរារាំងដោយសារឪពុកម្តាយរបស់នាងជាមិនខានជាស្រីដែលប្រកបរបរចិញ្ចឹមជីវិតក្នុងឧស្សាហកម្មនៃភាពរីករាយក្នុងប្រទេសកម្ពុជា ប្រហែលជាមុខរបរមួយនេះ មិនធ្វើអោយគេកោតសរសើរឡើយ ។ មិនដូចនៅសហរដ្ឋអាមេរិក ដែលអ្នកភ្លេងតារាសម្តែង ( តនៅទំព័រទី១២ )

PHNOM PENH express
PHNOM PENH EXPRESS
ក្រុមហ៊ុនទទួលផ្ញើប្រាក់ និងលក់សំបុត្រយន្តហោះ
2140E. Anaheim St., Long Beach CA 90804. Tel: (562) 434-3322
Mon-Sat: 9am-6pm Sunday: 10am-5pm (562) 434-3760

Law Offices of Boroth Chay
No Recovery . No Fees ! New Local
2501 Cherry Ave, ste.245, Signal Hill, CA 90755
Office: (562) 997-8500 . Direct: (562) 453-5898

TOP AUTO INSURANCE AGENCY
Free Quote, Low Rates, Why pay more
LOW COST LOW DOWN LOW MONTHLY
AUTO-LIFE-HEALTH-HOME-COMMERCIAL
Tiffany Prak
Agent/Broker Lic.0E44334
2760E. Spring St., Ste 140, Long Beach, CA 90806
Tel: (562) 989-1800 Cell: (562) 230-5100

FARMER INSURANCE
Douglas Horn Agency
License #0B83665
Life Insurance, Home Insurance, Business Insurance, Auto Insurance, Health Insurance, One Stop Service, Bail Bond,
1360E Anaheim St., Ste 203, Long Beach CA 90813
Tel: (562) 591-3100 Fax: (562) 591-3911

State Farm
Peter Kong Insurance Agency
Business Liability Insurance
Auto Insurance
Home Insurance
Life Insurance
Health Insurance
Apartement Insurance
Disability Insurance
Family & Individual Coverage
Sawannara + Sokha
(Notary Public)
2750E. Spring Street, Suite 201, Long Beach, CA 90806
Tel: (562) 426-9189 Fax: (562) 426-4669


EVA AIR
777-300ER
ក្រុមហ៊ុនអង្គរទេសចរណ៍
Angkor Travel
ការជ្រើសរើសតែមួយគត់សំរាប់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា
ទទួលបំរើកិច្ចការធ្វើដំណើរក្នុងសហរដ្ឋ និងអន្តរជាតិ ។
តម្លៃសំបុត្រលក់ចុះថ្លៃជាពិសេសសំរាប់ការធ្វើដំណើរក្នុងស្រុកចេញពី ចំណតយន្តហោះ LAX ទៅកាន់គ្រប់ទីក្រុងក្នុងសហរដ្ឋអាមេរិក ។
មានលក់កាតសំរាប់ទូរស័ព្ទជុំវិញពិភពលោក ( លក់ដុំ និងលក់រាយ) ។
ទទួលធ្វើ Re-Entry Permit លិខិតឆ្លងដែន ។
ទទួលធ្វើ Re-Entry Permit ប្រញាប់ជូនភ្លាមៗ!!!
ជួយរកតម្លៃសំបុត្រយន្តហោះថោកជាងគេទៅស្រុកខ្មែរតាមរយៈក្រុមហ៊ុន Eva Air , Cathay Pacific,Malaysia Air , Singapore Air.
តម្លៃពិសេស $890 សូមអញ្ជើញទាក់ទងនាងខ្ញុំ
Tel: (562) 599-0877 , Fax: (562) 599 4758
1569E, Anaheim St.,C Long Beach ,
CA 90813 (កាច់ជ្រុងផ្លូវ Anaheim & Walnut)
Cellphonatic
Wireless Super center
យើងខ្ញុំមានលក់កាតទូរស័ព្ទ ទិញដាក់បញ្ចូលទឹកលុយទៅក្នុងទូរស័ព្ទដៃ និងទូរស័ព្ទនៅផ្ទះបានភ្លាមៗ!!!
NO CONNECTION FEE !
NO EXPIRATION DATE !
metroPCS
No te limites.
FREE PHONE !!!
តម្លៃត្រឹមតែ $30 ក្នុងមួយខែ !
NOKIA 5300
NOKIA 5200
NOKIA
NOKIA 6070
NOKIA 6233
NOKIA 5288

# សហរដ្ឋអាមេរិកបោះឆ្នោតប្រធានាធិបតីឆ្នាំ២០០៨

***ដោយ : ពិន សំខុន***

ឆ្នាំ២០០៨ ខែវិច្ឆិកាខាងមុខនេះ សហរដ្ឋអាមេរិកនឹងធ្វើការជ្រើសរើសប្រធានាធិបតីថ្មីមួយ ជំនួសលោក ជច ប៊ូស ដែលបានទទួលភារៈដ៏ខ្ពង់ខ្ពស់បំផុតនេះ អស់រយៈពេល៨ឆ្នាំមកហើយ ។

តើនរណានឹងក្លាយជាបេក្ខជនឱ្យអាមេរិកាំងបោះឆ្នោតឱ្យ ? នៅពេលនេះ គណបក្សពីរ គឺគណបក្សសាធារណៈរដ្ឋ ហើយនឹងគណបក្សប្រជាធិបតេយ្យ កំពុងធ្វើការជ្រើសរើសបេក្ខជនរបស់ខ្លួន ដោយការបោះឆ្នោតជុំទី១ (Primary) យ៉ាងសកម្ម ។ នៅបីរដ្ឋដំបូងនៃ Primary នេះ ខាងគណបក្សប្រជាធិបតេយ្យមានលេចមុខសមាជិក


John Mcaim (Repuplican Party)


Hillary Clinton (Democratic Party)


Obama (Democratic Party)

ព្រឹទ្ធសភាពីររូបម្នាក់ជាស្ត្រីឈ្មោះ ហ៊ីឡារី គ្លីងតុន ជាភរិយាអតីតប្រធានាធិបតី គ្លីងតុន និងព្រឹទ្ធសភាម្នាក់ ទៀតស្បែកខ្មៅឈ្មោះ បារ៉ាក់ អូបាម៉ា (Barack Obama) រីឯសមាជិកម្នាក់ទៀតឈ្មោះ ផន អេដវ៉ដ ក៏ស្ថិតនៅចំណោមថ្នាក់ទី៣ កៀកគ្នានឹងអ្នកទាំងពីរខាងលើដែរ ។

រីឯគណបក្សសាធារណៈរដ្ឋ ក៏មានលេខមុខសមាជិកព្រឹទ្ធសភាបីនាក់ ដាច់គេដែរ គឺលោក ជន ម៉ាកេន លោក មីត រុនីយ និងលោក ម៉ៃ ហកបីបរ ។ រីឯសមាជិកពីរនាក់ទៀត ដែលគួរជាទីសង្ឃឹមដែរនោះ គឺលោក រ៉ូឌី គូលិកយានី និងលោក ហ្វ្រិត ធំសុន ឥឡូវនេះទទួលសន្លឹកឆ្នោតតិចតួច ។

ការបោះឆ្នោតប្រធានាធិបតីអាមេរិកាំង ជុំទី១លើកនេះ មានស្ត្រីភេទដំបូងបង្អស់មកឈរឈ្មោះ ហើយនឹងជនជាតិស្បែកខ្មៅក៏មានប្រជាប្រិយភាពក៏ចូលមកប្រជែងនឹងគេដែរ ។ ពលរដ្ឋអាមេរិកាំងជាម្ចាស់ឆ្នោត កំពុងផ្ចង់អារម្មណ៍ចម្រាញ់យក

( តទៅទំព័រទី១១ )

ទស្សនៈ នយោបាយ

# តើ ហ៊ុន សែន ពិតជាបន្ត ដៃគូនឹងហ្វ៊ុនស៊ិនប៉ិចទៀតទេ ?

*Long Beach*, ***មាជ សុវណ្ណារ៉ា***

ថ្មីៗកន្លងទៅនេះ នាយករដ្ឋមន្ត្រីខ្មែរលោក ហ៊ុន សែន ថ្លែងប្រាប់អ្នកកាសែតថា បើហ្វ៊ុនស៊ិនប៉ិចគ្មានមួយអាសនៈនោះ វាជាការលំបាកក្នុងការធ្វើ


លោក ញឹក ប៊ុនឆៃ


លោក ហ៊ុន សែន

ជាដៃគូក្នុងរាជរដ្ឋាភិបាលអាណត្តិទី៤ ព្រោះរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវធ្វើការផ្ទេរផ្តងសមាជិករាជរដ្ឋាភិបាល តែជាមួយគណបក្សដែលមានអាសនៈនៅក្នុងសភាតែប៉ុណ្ណោះ ។

សំដីរបស់នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ថ្លែងបែបនេះ ត្រូវពួកអ្នកវិភាគនយោបាយមើលឃើញថា ហ៊ុន សែន ហាក់កំពុងធ្វើការព្រមានចំពោះដៃគូរបស់ខ្លួន ដែលរួមរស់ជាមួយគ្នាអស់៣អាណត្តិមកហើយនោះ ពីការចង់រលាស់ដៃពីហ្វ៊ុនស៊ិនប៉ិច ។ ខណៈដែលការបោះឆ្នោតសកលឆ្នាំ២០០៨ ជិតចូលមកដល់នាខែកក្កដាខាងមុខ ។

ពួកអ្នកវិភាគនយោបាយមើលឃើញថា បើគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន នៅបន្តភាពស្មោះត្រង់ក្នុងភាពជាដៃគូក្នុងរាជរដ្ឋាភិបាលជាមួយគ្នានោះ គឺពួកមន្ត្រីធំៗ ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬឥស្សរជនជាន់ខ្ពស់ដទៃទៀតរបស់ហ្វ៊ុនស៊ិនប៉ិចមិនត្រូវបាន ហ៊ុន សែន ដកហូតនោះទេ ។ ហើយបើពិតថាការដកហូតដើម្បីផ្លាស់ប្តូរ ព្រោះតែអសមត្ថភាព

( តទៅទំព័រទី១១ )





DARANY'S FASHION
ហាងយើងខ្ញុំមានលក់
.Beauty Suplies . Phone Card .
ម៉្សៅលាបបំបាត់មុន.ជាំមុខ. ឡេចិញ្ចឹមស្បែកឱ្យបានស្អាត
ហាងយើងខ្ញុំមានសំលៀកបំពាក់ខ្មែរដែលរចនាម៉ូដដោយជាងចំណាន១ ធ្វើពី
ហូល ផាមួង និងក្រណាត់ប៉ាក់ មានតុបតែងមុខសំរាប់ពិធីផ្សេង១.មានលក់ថ្នាំ
បញ្ចុះទម្ងន់ មានទទួលផ្ញើរអីវ៉ាន់ និងគ្រឿងសម្ភារៈផ្សេង១ទៅកាន់ស្រុកខ្មែរ ។
.ថ្នាំម៉ាស្សាត្រាំទឹកដោះគោ .ឡេម្សៅល្បៀតលាបខ្លួន
.គ្រឿងអលង្ការធ្វើពីប្រាក់ .គ្រឿងលំអគ្រប់ប្រភេទ
បញ្ចុះតម្លៃ
ពិសេស
១៥%
សូមអញ្ជើញ
ទៅហាងយើងខ្ញុំ
ដោយមេត្រី !
DARANY'S FASHION
2201E. Anaheim St.# 102 . Long Beach, CA 90804
Store : (562) 438-2488 . Cell: (562) 786-2095

# ទៅលេងក្រុងចិនញ៉ាំគុយទាវបាត់ដំបង ទិញម្ហូបផ្សារខ្មែរហោវ៉ៃ

*San Gabriel,* **រ៉ាឆាថ**

ជារៀងរាល់ចុងសប្តាហ៍ គេសង្កេតឃើញបងប្អូនខ្មែរយើង មិនថាជិតឆ្ងាយក្នុងក្រុង Los Angeles ឬ Long Beach, Santa Ana ក្តី បានចាប់យកដំណើរកំសាន្តក្នុងជីវិត ដែលបានសំរាកពីការងារ តែងយកតំបន់ក្រុងចិនជាការដើរទេសចរ ដោយទស្សនាកំសាន្ត ចូលហាងផ្សារ ឬភោជនីយដ្ឋាន ដើម្បីទិញរបស់របរអនុស្សាវរីយ៍ សម្លៀកបំពាក់ គ្រឿងអលង្ការ ម្ហូបអាហារ និងញ៉ាំបាយ គុយទាវ ។



អតិថិជនចូលទិញទំនិញក្នុងផ្សារ




ផ្សារខ្មែរហោវ៉ៃ

ការបរិយាយនេះ យើងគ្រាន់តែលើកនូវតំបន់ក្រុងចិនមួយ ក្នុងចំណោមក្រុងចិនជាច្រើនទៀត គឺក្រុងចិន San Gabriel ដែលធ្វើដំណើរទៅកាន់ទីនោះ តាម Freeway 710, 10 ។ នៅទីនោះហាងទំនិញ កន្លែងរកស៊ីជំនួញចម្រុះសព្វសារពើសងខាងផ្លូវជាច្រើនប្រឡោះ ដែលរំលេចទៅដោយអក្សរចិនពណ៌ក្រហមព្រោងព្រាត បញ្ជាក់ពីឈ្មោះនៃមុខរបរជួញដូររបស់ពួកជនជាតិចិន ។ ប៉ុន្តែអ្វីដែលយើងមោទនភាពសំរាប់ទីនោះ គឺមានបងប្អូនខ្មែរជាច្រើនគ្រួសារដែរ បានរស់នៅរកស៊ីប្រកួតប្រជែងជួញដូរជាមួយពួកអ្នកជំនួញចិន ដូច

( តទៅទំព័រទី០៧ )

# កុមារខ្មែរដង្ហោយរកការជួយសង្គ្រោះ ដើម្បីបានចូលរៀន

**ដោយ : រ៉ាឆាថ**

ក្នុងដំណើរទៅលេងស្រុកកំណើតនៅឯប្រទេសកម្ពុជាដ៏សន្តិភាពមួយខ្ញុំបានទៅដល់ទីជនបទដាច់ស្រយាលដោយទឹកចិត្តបានរុញឱ្យរូបខ្ញុំស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន នៅពេលដែលក្មេងជាច្រើនមកព័ទ្ធជុំវិញខ្លួនខ្ញុំ ហើយប្រាប់ខ្ញុំថា ពួកគេពុំបានទៅសាលារៀនទេ ព្រោះតែបញ្ហាជីវភាពឪពុកម្តាយពួកគេក្រីក្រគ្មានលទ្ធភាពទិញសំលៀកបំពាក់សំភារៈសិក្សា ដែលសំដីទាំងអស់នោះបានធ្វើឱ្យខ្ញុំមានក្តីអាណិត និងការព្រួយបារម្ភបំផុតពីអនាគតរបស់ពួកគេ ដែលងាយនឹងធ្លាក់ទៅរកភាពអវិជ្ជា (អនក្ខរជន) ។ នេះ គឺជាសំដីដ៏អួលដើមករបស់លោក អ៊ុក ណូមីយ៉ា បានថ្លែងប្រាប់អ្នកកាសែតខ្មែរប៉ុស្តិ៍ ។



ខ្ញុំជាបារាំងតែបេះដូងខ្មែរ



លោក អ៊ុក ណូមីយ៉ា និង លោកស្រី តេរីស សប្បុរសជនជាតិបារាំង

លោក អ៊ុក ណូមីយ៉ា បានបន្តថា ដោយឃើញទិដ្ឋភាពផ្ទាល់ពីភាពវេទនារបស់កុមារ គឺជាវិប្បដិសារីចំពោះគាត់ក្នុងនាមជាកូនខ្មែរម្នាក់បានធ្វើឱ្យរូបគាត់ និងស្ត្រីជាតិបារាំងម្នាក់ទៀតបង្កើតនូវកម្មវិធីកុមារកម្ពុជា (Cambodia's Kids Program) តាំងពីឆ្នាំ២០០៦ ក្នុងបំណងឧបត្ថម្ភកុមារក្រីក្រឱ្យបានសិក្សាចប់សាលាបឋមសិក្សា ឧបត្ថម្ភសំភារៈក្មេងលេងទាក់ទងក្នុងផ្នែកសិក្សា (Educational Toys) ដល់សាលាមត្តេយ្យដ្ឋាន

( តទៅទំព័រទី០៩ )


## LAW OFFICES OF FRANK G. PIAZZA, JR. & ASSOCIATES

-PROFESSIONAL AGRESSIVE. DISCREET,EXPERIENCE, REPRESENTATION

**CRIMINAL LAW AND FAMILY LAW ARE STRICTLY HANDLED BY AN UNASSOCIATED ATTORNEY**

- Serious accident **Required Experienced and Compentent Representation** to make sure you received adequate compensation for your injuries. Otherwise, you(the injured person) could lose thousands of dollar with **the Incompentent and Unexperienced Representation.**
- I Speak Combodian/English fluently, I have many years of experience on dealing and negotiating for maximum settlement possible with insurance compenies for our clients.
- Appointments are available for you to come in office after working hour and weekend. Please call in advance.

100 OCEANGATE,SUITE 525,
LONG BEACH.CA 90802
TEL:(562) 708-3721, Fax: (562) 437-8425,
Email:MORALAW5@YAHOO.COM



MORA MAO



FRANK PIAZZA



DOUGLAS MELSON

- ត្រូវរបួសធ្ងន់ធ្ងរត្រូវឱ្យមានអ្នកតំណាងមានសមត្ថភាព និងមានការពិសោធន៍យ៉ាងបរិបូណ៌ ដើម្បីទារសំណងឱ្យបានសមរម្យនឹងរបួសលោកអ្នកពុំនោះទេ លោកអ្នកនឹងត្រូវខាតបង់ប្រាក់ច្រើនពាន់ដុល្លារ កាលបើអ្នកតំណាងក្តីរបស់លោកអ្នកអសមត្ថភាព និងខ្វះការពិសោធន៍ ។
- ខ្ញុំបាទស្ទាត់ជំនាញខាងភាសាខ្មែរ,អង់គ្លេសមានទេពកោសល្យខាងពិភាក្សាចរចាក្នុងរឿងក្តីរបស់លោកអ្នក ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកន្លែងមកហើយ ។
- កិច្ចការ ហ្មត់ចត់ ម៉ឺងម៉ាត់ រហ័សទាន់ចិត្តទាំងក្នុង និងក្រៅតុលាការ ។
- លោកអ្នកអាចធ្វើការណាត់ជួបខ្ញុំបាទ ក្រៅម៉ោងធ្វើការ ឬចុងសប្តាហ៍ ។

***Our Recent successful cases :***

- **$1,000,000.00,** Bicylist Vs Truck Case, Guranteed annuity.
- **$100.,000.00,** Dog Bites Vs Home Owner Insurance of the apt.complex.
- **$250,000.00,** Auto Vs Auto, Settlement

**INJURY / DEATH CASES:**

- Wrongful death
- Broken / fracture bones
- Amputation / Paraplegia
- Auto / Bicycle / Motorcycle
- Uninsured Motorist
- Dog Bites
- All insurance Disputes

**CRIMINAL/STATE &FEDERAL:**

- Drug offense
- Murder
- Rape
- Kidnapping
- Fraud
- DMV Hearings
- Hit & Run
- Assault & Battery

**FAMILY LAW:**

- Child Custody
- Divorce
- DA Child Support
- Legal Separation



# ខ្មែរគ្មានដីធ្វើស្រែ... បែរជាយួនមានដីសម្បទាន

*Long Beach,* **មាជ សុវណ្ណារ៉ា**

-ទាំងអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយមួយចំនួនបានប្រឆាំង និងទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លុបចោល



ដីសម្បទានរបស់ក្រុមហ៊ុនយួន

កិច្ចសន្យាដីសម្បទានព្រៃឈើចំនួន១០ ដែលបានប្រគល់ទៅឱ្យក្រុមហ៊ុនវៀតណាម ដោយបានចោទប្រកាន់ថា អាចនឹងមានការហូរចូលនូវជនអន្តោប្រវេសន៍ និងសញ្ជាតិគូបនីយកម្ម ដែលអាចនឹងកើតមានឡើងតាមរយៈការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងកសិកម្មនោះ ។

-ការប្រឆាំង និងទាមទារនេះ បានកើតមានឡើងក្រោយពីរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់កិច្ចសន្យាដីសម្បទានកសិកម្មទៅឱ្យក្រុមហ៊ុនវៀតណាមចំនួន១០ ជាពិសេសក្រុមហ៊ុនយោធិនវៀតណាមចូលនិវត្តន៍ លើផ្ទៃដីចំនួន១២០.០០០ហិចតា នៅក្នុងខេត្តចំនួន៣ គឺខេត្តកំពង់ចាម ក្រចេះ និងកំពង់ធំ ដែលកិច្ចសន្យាមានរយៈពេលពី៧០ឆ្នាំ ទៅ៩៩ឆ្នាំ ស្មើមួយអាយុជីវិតមនុស្ស។

-គណបក្សនរោត្តម រណឫទ្ធិ បានចេញសេចក្តីថ្លែងការរបស់ខ្លួនកន្លងមក ដោយចោទប្រកាន់ថា បច្ចុប្បន្ននេះ ដីសម្បទានទៅឱ្យក្រុមហ៊ុនវៀតណាម បានកំពុងតែកាប់បំផ្លាញព្រៃឈើនៅក្នុងខេត្តទាំង៣នេះ ដោយគ្មានការត្រួតពិនិត្យឱ្យបានត្រឹមត្រូវក្រោមរូបភាពកាប់ឆ្ការ ដើម្បីដាំដើមកៅស៊ូ។ ប៉ុន្តែ ការរិះគន់នេះ ពុំបានបង្ហាញពីស្ថិតិទំហំព្រៃឈើដែលត្រូវបំផ្លាញ និងបាត់បង់ទេ ។

-អ្នកនាំពាក្យគណបក្សនរោត្តមរណឫទ្ធិ បានលើកឡើងថា ការផ្តល់ដីសម្បទានរបស់រដ្ឋាភិបាលទៅឱ្យក្រុមហ៊ុនវៀតណាម គឺបានផ្តល់កន្លែងណា ដែលមានព្រៃក្រាស់ធំៗ ដែលហ៊ុំព័ទ្ធទៅដោយឈើល្អប្រណិតៗ ដែលថា ការធ្វើឱ្យវិចវិលដល់ព្រៃឈើកម្ពុជា និងថាបានប៉ះពាល់បញ្ហាបរិស្ថានទឹកជំនន់ បាត់បង់សេដ្ឋកិច្ចសង្គមជាតិ។

-មន្ត្រីក្រុមអង្គការសិទ្ធិមនុស្ស អាតហុក និង លីកាដូ បានរិះគន់ថា ការធ្វើនេះ វាជាការរំលោភសិទ្ធិមនុស្ស និងអយុត្តិធម៌សំរាប់ពលរដ្ឋកម្ពុជាក្រីក្រ ដែលគ្មានដីធ្វើស្រែ និងដីត្រូវបានគេរំលោភបំពាន ដើម្បីរឹបអូសយកទៅឱ្យក្រុមហ៊ុនសម្បទាន ។

-នៅក្នុងសេចក្តីថ្លែងការរបស់គណបក្សសិទ្ធិមនុស្ស ដែលកាសែតខ្មែរប៉ុស្តិ៍ទទួលបានតាមសារ E-mail បានបង្ហាញនូវការប្រឆាំងទៅនឹងអាជ្ញាធរ ខេត្តកំពង់ធំ ដែលបានរុះរើផ្ទះប្រជាពលរដ្ឋ នៅក្នុងឃុំ ក្រយៀ ស្រុកសន្ទុក ខេត្តកំពង់ធំ ដើម្បីយកដីទៅឱ្យក្រុមហ៊ុនចំការកៅស៊ូវៀតណាម ឈ្មោះ តាន់ បៀន និងធ្វើការបិទផ្លូវ មិនឱ្យប្រជាពលរដ្ឋទៅផ្សារទិញស្បៀងអាហារបាន ។

-សេចក្តីថ្លែងការនោះ បានចាត់ទុកសកម្មភាពនោះ គឺជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ទាក់ទងទៅនឹងបញ្ហាដីធ្លី ជំរក និងសេរីភាពក្នុងការដើរហើរ ដែលគណបក្សសិទ្ធិមនុស្សមិនអាចទទួលយកបានជាដាច់ខាត។

-ប៉ុន្តែ ទោះបីជាយ៉ាងណា គណបក្សសិទ្ធិមនុស្ស គាំទ្ររាល់ការអភិវឌ្ឍន៍ទាំងឡាយណា ដែលបំរើផលប្រយោជន៍ឱ្យប្រជាពលរដ្ឋ និងប្រទេសជាតិ ពោលគឺមិនប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងមិនមានការរំលោភលើសិទ្ធិមនុស្ស ។ ដោយសូមអំពាវនាវដល់រាជរដ្ឋាភិបាល មេត្តាចុះពិនិត្យដោះស្រាយជូនប្រជាពលរដ្ឋជាងមួយពាន់គ្រួសារ ដោយឈរលើគោលការណ៍ព្រមព្រៀងស្ម័គ្រចិត្តទៅវិញទៅមក និងបើកផ្លូវឱ្យអ្នកភូមិអាចធ្វើដំណើរចេញចូលបានជាប្រក្រតីឡើងវិញ។

-ទាំងអាជ្ញាធរដែនដីលោកអភិបាលខេត្តកំពង់ធំ ណាំ ទុំ និងអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ខៀវ កញ្ញារិទ្ធ ពុំអាចសុំទំនាក់ទំនងធ្វើសេចក្តីអធិប្បាយបានទេ ដោយទូរស័ព្ទរបស់លោកទាំងពីរគ្មានអ្នកទទួល ។

-មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាលោក ជាម យៀប ធ្លាប់បានអះអាងថា រាជរដ្ឋាភិបាលតែងតែគិតគូរជានិច្ច ចំពោះផលប្រយោជន៍ប្រទេស និងប្រជាពលរដ្ឋ ។ ដោយរូបលោករំពឹងថា ប្រទេសកម្ពុជានឹងមានផលប្រយោជន៍ច្រើន ចំពោះការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងកសិកម្ម ដល់ក្រុមហ៊ុន ឯកជននានា ដែលបានចូលមកវិនិយោគនៅក្នុងប្រទេសកម្ពុជា ។

-ខ្មែរប៉ុស្តិ៍ ពុំអាចទំនាក់ទំនងបានទេ ពីលោករដ្ឋមន្ត្រីក្រសួងកសិកម្ម ចាន់ សារ៉ុន ពីបញ្ហាការផ្តល់ដីសម្បទានឱ្យទៅក្រុមហ៊ុនជាប់ជំពាក់ជាមួយប្រជាពលរដ្ឋពីការបាត់បង់ដីធ្លី។

-បច្ចុប្បន្នប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់លោក ហ៊ុន សែន បានផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនចំនួន៥៩ ដែលមានផ្ទៃដីសរុបជាង៩៤៣ពាន់ហិកតា ក្នុងខេត្តចំនួន១៥ ដែលក្នុងនោះមានក្រុមហ៊ុនបរទេសចំនួន២៥ ។ ហើយក្រៅពីនោះ មានក្រុមឈ្មួញខ្មែរ ដែលស្និតបំផុតនឹងគណបក្សប្រជាជនកម្ពុជា ដែលរួមមានក្រុមហ៊ុនរបស់លីយ៉ុងផាត់, ម៉ុងឫទ្ធី, ឡៅម៉េងឃិន និង ម៉ែន សារុន ជាពិសេសក្រុមហ៊ុនភាពីម៉ិចរបស់យាយ ផូ ជាមនុស្សជំនិតរបស់លោក ហ៊ុន សែន មានសិទ្ធិទទួលបាននូវដីសម្បទានចំនួន៣១៥ពាន់ហិកតា ដែលក្រុមហ៊ុនភាគច្រើនមិនបានបង់ពន្ធចូលថវិការរដ្ឋទៀតផង។

-បញ្ហាដីធ្លីនៅកម្ពុជា កំពុងស្ថិតក្នុងភាពក្តៅគគុក ដែលចំណោទបញ្ហាសំរាប់ប្រជាពលរដ្ឋ ដែលកំពុងរងគ្រោះពីការបាត់បង់ដីធ្លី ស្រែចំការ ផ្ទះសម្បែង ព្រោះតែទីផ្សារគួកជេដីឡើងថ្លៃខ្ពស់កប់ពពក ដែលជាការធ្វើឱ្យជនឆក់ឱកាសនិយមបង្កភាពវឹកវររំលោភបំពានយកដីប្រជារាស្ត្រ ដោយឃុបឃិតប្រព្រឹត្តអំពើពុករលួយ ត្រូវរ៉ូវជាមួយជនមានអំណាចមន្ត្រីសុរិយោដីក្រុមតុលាការក្នុងការធ្វើប្លង់ ឬសម្រេចក្តីដើម្បីបង្ហាញពីភាពស្របច្បាប់ ក្នុងបំណងផ្លូវអាក្រក់ឆក់យកដីធ្លីគេ។ ក៏ប៉ុន្តែបញ្ហានេះក៏វាមិនអត់ដែរទេ ចំពោះប្រជាពលរដ្ឋខ្លះខិលខូចទៅរស់នៅ ឬចាប់យកដីគេដើម្បីទុកលក់ ឬជាថ្នូរនឹងម្ចាស់ដី ពេលមានជម្លោះដីធ្លី ៕

# ជួបជាមួយគ្រូគុន ដំបងបូរាណ



គ្រូគុនដំបង ជាតិ សារឿត

*Long Beach,* **ករុណា**

ក្នុងកាយវិការលើកដំបងគុន ដែលមានទំហំប៉ុនកដៃកូនក្មេង ប្រវែងជាង២ម៉ែត្រ នៅចំពោះមុខអសនៈព្រះពុទ្ធរូប ក្នុងគេហដ្ឋានបុរសម្នាក់ មានមាឌធំក្រអាញ សក់រួញអង្ការដី សម្បុរខ្មៅ ដែលមានវ័យជាង៥០ឆ្នាំផ្លាយ បានធ្វើសកម្មភាពជាមួយនឹងដំបងគុន បញ្ចេញស្នៀតក្បាច់គុនទ្វារ២ រហូតដល់ទ្វារ៨ ឱ្យអ្នកកាសែតយើងមើលឃើញផ្ទាល់ពីយុទ្ធវិធីបង្ក្រាបសត្រូវ ដែលយើងគិតថា វាមិនមែនជារឿងងាយស្រួល ដែលមនុស្សគ្រប់រូបត្រូវចេះវាយឯកឯងបានទេ ។ ការនិយាយថា មិនជារឿងងាយស្រួលនោះ គឺត្រង់ន័យថា បើជនណាម្នាក់មិនចេះពីក្បាច់គុនដំបង ដោយចង់បង្កជាមួយអ្នកដែលចេះក្បាច់គុនដំបង វាជាការពិបាកក្នុងការចង់បៀតបៀនជីវិត ឬប៉ុនប៉ងវាយសំរុកឆក់យកការផ្តួលរំលំដៃគូ ព្រោះក្បាច់គុនដំបងបានស្តែងចេញឱ្យឃើញនូវចំណុចស្នៀតប្រយុទ្ធ គឺចំទិសដៅទៅលើខ្លួនសត្រូវមិនអាចតដៃបាន បើសិនអ្នកនោះដែលជាសត្រូវ ឬគូប្រកួតជាមនុស្សដំឡូងមូល ។

លោក ជាតិ សារឿត និយាយថា ការចេះក្បាច់គុនដំបងបែបបូរាណនេះ គឺជាបំណងប្រាថ្នាល្អចំពោះអ្នកដែលបានរៀនសូត្រ ដើម្បីជួយនូវកិច្ចការពារខ្លួន ចិត្តប្រាកដនិយមបង្កើនភាពថ្លៃថ្នូរ និងសេចក្តីអត់ធ្មត់ ។ ដូច្នេះ ការដែលគាត់ចេះក្បាច់គុនដំបងនេះ មិនមានគំនិតថា ខ្លួនចេះហើយ ចង់ទៅបង្ករឿងរ៉ាវជាមួយអ្នកដទៃ ឬសំដែងការអួតអាងពីមោទនភាពអ្វីទេ ។

លោក ជាតិ សារឿត បន្តថា ឥឡូវនេះ គាត់បានក្លាយជាគ្រូគុនដំបង ដោយឥតគិតកម្រៃ ដើម្បីបង្រៀនដល់កូនខ្មែរជំនាន់ក្រោយ ពិសេសខ្មែរយើងនៅក្នុងសង្គមអាមេរិក ដែលងាយនឹងបាត់បង់វប្បធម៌ខ្លួន ព្រោះតែការដើរតាមគន្លងអារ្យធម៌បច្ចឹមប្រទេស ដើម្បីចង់រក្សានូវក្បាច់គុនបុរាណខ្មែរ ដែលជាក្បាច់គុនដ៏សំខាន់ ដែលបានចាស់ៗជំនាន់មុនយកទៅប្រើប្រាស់ការពារទប់ទល់សត្រូវក្នុងបុព្វហេតុមាតុភូមិខ្លួន ។

គ្រូគុនដំបងបានថ្លែងថា ជាង៣ឆ្នាំកន្លងទៅនេះ គាត់បានកំពុងតែចងក្រងជាឯកសារ និងសៀវភៅពីក្បាច់គុនដំបងចាប់ពីទ្វារ២រហូតដល់ទ្វារ៨ជិតចប់ ហើយបំណងរក្សាទុក ( តនៅទំព័រទី០៧ )

# កុមារខ្មែរដេវង្ហោយរកការជួយ...

និងការឧបត្ថម្ភសាលាខាងផ្នែកអនាម័យ ដោយផ្តល់អណ្តូងទឹក និងសង់បង្គន់ជាដើម ។

ក្នុងឆ្នាំ២០០៨ នៃកម្មវិធីកុមារកម្ពុជាគ្រោងចាប់ផ្តើមជួយផ្នែកសំភារៈសិក្សាសំភារៈបង្រៀន ជីកអណ្តូងទឹកជួសជុលបន្ទប់រៀនឱ្យបានជិតសមរម្យ និងបង្កើតបង្គន់ប្រុស-ស្រី តាមបែបអនាម័យ បង្កើតបណ្ណាល័យចល័ត (Mobitel Library) ។

លោក អ៊ុក ណូមីយ៉ា ថ្លែងថា គំរោងការណ៍នេះ មិនមែនមានបំណងចង់ធ្វើជំនួសរាជរដ្ឋាភិបាលកម្ពុជានោះទេ ហើយក៏គ្មានបំណងអ្វីដែលចង់ប៉ះពាល់ ឬជំពាក់នឹងបញ្ហានយោបាយណាមួយទេ ។



គឺបំណងប្រាថ្នាដ៏ល្អបំផុតរបស់គាត់ គឺជួយដល់កុមារឱ្យបានចេះអានចេះសរសេរអក្សរ និងចេះគណនាលេខនព្វន្តតែប៉ុណ្ណោះ ។ ចំណែកថវិកាដែលជួយឧបត្ថម្ភគំរោងការនេះ គឺបានមកពីសំណាក់ពួកគាត់ទាំងពីរនាក់ សប្បុរសជន អ្នកជំនួញ និងក្រុមហ៊ុនសមាគមជាច្រើន ។

ក្មេងៗដែលរស់នៅស្ថិតដាច់ឆ្ងាយពីទីក្រុង ឬទីរួមស្រុកខេត្ត ទូទាំងប្រទេសកម្ពុជាប្រមាណ៤០% បានបោះបង់ការសិក្សា ព្រោះតែចំណោទជីវភាពគ្រួសាររបស់ពួកគេ ដែលមានប្រាក់ចំណូលក្នុងមួយថ្ងៃស្មើរតែមិនបាន១ដុល្លារផងនោះ ។ ដែលបញ្ហានេះ ជាឧបសគ្គសំរាប់កុមារក្នុងតំបន់ទាំងនោះ ពុំបានចូលរៀន ព្រោះតែគ្មានលុយទិញសំភារៈសិក្សា សៀវភៅ ប៊ិច ខ្មៅដៃ និងឯកសណ្ឋានសាលា ។

បើទោះបីរាជរដ្ឋាភិបាលកម្ពុជាបានអួតអាងថា ខ្លួនកំពុងតែគិតគូរពីវិស័យអប់រំ ពិសេសការកសាងសាលារៀនច្រើនហើយក៏ដោយ ។ ប៉ុន្តែបញ្ហាក្មេងអត់ចូលសាលារៀន នៅតែមានកំរិតគួរឱ្យព្រួយបារម្ភ ព្រោះតែចំណោទជីវភាពគ្រួសារដែលរងទុក្ខដាច់បាយក្រហាយទឹក ដោយក្មេងៗទាំងនោះ ត្រូវបង្ខំចិត្តឈប់រៀន ឬមិនចូលរៀននៅពេលគ្រប់អាយុ ដើម្បីជួយរកចំណីអាហារសម្រាលដល់ឪពុកម្តាយសំរាប់ក្រពះឱ្យជីវិតរស់មួយថ្ងៃសំរាប់មួយថ្ងៃ ។

កុមារកម្ពុជារាប់ម៉ឺននាក់ ដែលរស់នៅជាមួយឪពុកម្តាយ ក្រោមបន្ទាត់ជីវភាពក្រីក្រប្រមាណ ៤០% ត្រូវឃ្លាតស្រុកកំណើត ស៊ីឈ្នួលគេ កាយសំរាមដែលមានក្លិនស្អុយ ដើម្បីស្វែងរកម្ហូបអាហារសំរាប់រស់ ហើយកុមារខ្លះទៀត ត្រូវគេជួញដូរ

( តនៅទំព័រទី១២ )


Unipaq Realty & Financial

Complete Real Estate Services

សូមអញ្ជើញដោយមេត្រីភាព !

-បំរើកិច្ចការដោះលក់ដូរទិញផ្ទះទូទៅ

-អ្នកប្រឹក្សាពិគ្រោះយោបល់នៃការខ្ចីប្រាក់



David Kuoch

*Real Estate Agent*

*Loan Consultant*

Cell: (714) 351-2803

Office: (714) 892-2070

Fax: (714) 893-2059

Residence: (714) 774-4061

12062 Valley View St., Suite 204B

Garden Grove, CA 92845

Email: davidkuoch@sbcglobal.net



ក្រុមតន្ត្រីសោភារី

Sopheary Band

រីករាយបំផុតក្នុងការប្រគំតូរ្យតន្ត្រីជូនលោក-អ្នកក្នុងពិធីបុណ្យផ្សេងៗ ។

សូមទាក់ទងអ្នកគ្រប់គ្រង :

Charlie Ouk 562-591-2011

Cell: 562-400-7678





# សមាគមខ្មែរនៅទ្វីបអាមេរិក

# CAMBODIAN ASSOCIATION OF AMERICA

## A Nonprofit Human Services Organization

2 Hearts, 2 Hands, 1 Purpose: Building a Strong, Healthy Marriage

## លំនាំសុភមង្គលនៃស្វាមីភរិយា និងគ្រួសារ

***តពីលេខមុន***

* **ចំពោះស្ត្រី :**

- ការសប្បាយរីករាយនឹងទំនាក់ទំនងដ៏ល្អកល្អើននេះ
- មានសុខភាពល្អសប្បាយរីករាយ ទាំងផ្លូវកាយ និងផ្លូវចិត្ត
- ភាពធូរធារជ្រះស្រលះក្នុងចិត្ត
- មានកំរិតទាបចំពោះគ្រោះថ្នាក់កើតឡើងដោយអំពើហឹង្សាគ្រួសារ និងការរំលោភបំពាន
- បំពានតាមផ្លូវភេទ ហើយនឹងឧក្រិដ្ឋកម្មមានកំរិតទាប
- ជៀសវាងបំណងធ្វើអត្តឃាត
- អាចកាត់បន្ថយជម្ងឺផ្លូវភេទ
- ហើយមានទំនាក់ទំនងល្អជាមួយគ្រួសារ និងកូនចៅ

* **ចំពោះបុរស :**

- មានអាយុយឺនយូរ
- សុខភាពល្អខាងផ្លូវកាយ និងផ្លូវចិត្ត
- ភាពធូរធារជ្រះស្រលះក្នុងចិត្ត
- មានលំនឹងការងារ
- អាចរកបានប្រាក់ចំណូលខ្ពស់
- កាត់បន្ថយគ្រោះថ្នាក់ដែលកើតមកពីការប្រើគ្រឿងញៀន និងស្រវឹង
- ស្រឡាញ់ស្មោះស្ម័គ្ររួមរ័កនឹងគ្នាជាទីគាប់ចិត្ត
- ស្ងប់ខ្ចឹមនឹងអំពើហឹង្សា
- ជៀសវាងធ្វើអំពើអត្តឃាត
- ជៀសវាងអំពើមិនគប្បីក្នុងសាលារៀន
- មានកំរិតទាបក្នុងការប្រើប្រាស់គ្រឿងញៀន និងស្រវឹង
- ជៀសវាងការគេចវេសសាលា ហើយដើរប៉ោឡែ
- ការមានផ្ទៃពោះក្នុងយុវវ័យ ឬធ្វើឱ្យមានផ្ទៃពោះមានកំរិតទាប
- ការរស់នៅក្នុងភាពក្រីក្រមានកំរិតទាប

✦ ស្ត្រីដែលរៀបការហើយ បានទទួលភាពសប្បាយរីករាយជាងស្ត្រីមិនទាន់រៀបការ ទោះបីគេសង្កេតឃើញថា បុរសហាក់បីដូចជាបានទទួលបានគុណប្រយោជន៍ជាងស្ត្រីក្តី ប៉ុន្តែយើងអាចសន្និដ្ឋានបានថា អាពាហ៍ពិពាហ៍បាននាំមកនូវគុណប្រយោជន៍សុភមង្គលដល់អ្នកទាំងពីរដូចគ្នា ។ ប៉ុន្តែបើមានសុភមង្គលក្នុងគ្រួសារវិញ បុរសដូចជាបានទទួលគុណប្រយោជន៍ច្រើននេះ ប្រហែលមកពីកត្តាពីរ : **ទី១** : បុរសខ្លួនមួយ (បុរសមិនទាន់រៀបការ ឬ ក្រោយពេលលែងលះគ្នា) ជាទូទៅធ្លាប់មានជីវិតរស់នៅលំបាក "មានទំលាប់អាក្រក់ក្នុងការបរិភោគ" ព្រមទាំងប្រព្រឹត្តនឹងអំពើមិនល្អ "ផឹកសុរា, ជក់បារី" ។ ភាគច្រើនមិនកើតឡើងចំពោះស្ត្រីភេទទេ ប្រពន្ធថែមទាំងយកចិត្តទុកដាក់ចំពោះប្តី ឯប្តីវិញមិនសូវបំពេញបានបំណងរបស់ប្រពន្ធវិញឡើយ ។ ទោះបីយ៉ាងណាក៏ដោយអាពាហ៍ពិពាហ៍បាននាំមកនូវគុណប្រយោជន៍ចំពោះបុរស និងស្ត្រីទាំងពីរប្រភេទ ។ ចំពោះបុរសវិញ មានការខាតបាត់បង់ច្រើន បើមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ។

**តទៅលេខក្រោយ**

Funding for This project is provided by U.S Department of Health and Human Services Administration for Children and Families Grant #90FE0065

ចំណងដៃពិសេសពីផលិតកម្មមាតុភូមិ

2517 E. ANAHEIM STREET LONG BEACH, CA 90804
Tel: (562) 968-7188 • (562) 438-8602



CD 1 & CD 3 ON SALE NOW



កម្រង CD អធិរាជសម្លេងមាសអមដោយអត្ថាធិប្បាយ លេខ១ & ៣ បានចរាចរនៅលើទីផ្សារហើយ!

ផលិតកម្មមាតុភូមិ សូមស្វាគមន៍ !

## រូបអង្គរវត្តត្រូវគេបោះពុម្ព...

ជាប់ព្រំដែនយួន ប៉ុន្មានថ្ងៃចុងក្រោយនេះ ។

ក្រុមអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយនានា បានចាត់ទុកថា នេះ គឺជាទង្វើថ្មីមួយ ដែលក្រុមហ៊ុនធ្វើស្បែកជើងបានធ្វើឱ្យប៉ះពាល់ដល់កិត្តិស័ព្ទជាតិខ្មែរ និងមើលងាយដល់រដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ក៏ដូចជារំលោភលើសិទ្ធិសេរីភាព វប្បធម៌ប្រពៃណីជាតិខ្មែរ ។

នៅក្នុងបញ្ហានេះ គេឃើញគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា បានចេញសេចក្តីថ្លែងការណ៍ជាបន្ទាន់មុនគេ ដោយដាក់ការថ្កោលទោសយ៉ាងខ្លាំងក្លាដល់ក្រុមហ៊ុនផលិតស្បែកជើងនេះ និងសូមឱ្យរាជរដ្ឋាភិបាលខ្មែរ ពិសេសអាជ្ញាធរខេត្តស្វាយរៀងធ្វើការស្រាវជ្រាវស៊ើបអង្កេតជាបន្ទាន់ថា តើក្រុមហ៊ុនផលិតស្បែកជើងសង្រែកនេះ បានផលិតនៅប្រទេសណា ? ដើម្បីចាត់វិធានការបញ្ឈប់ការផលិតស្បែកជើងតទៅទៀត ដោយទាមទារឱ្យមានការសុំទោសជាសាធារណៈ និងបង់ពិន័យជាប្រាក់សងជម្ងឺចិត្តដល់ប្រជាពលរដ្ឋខ្មែរ ។

ពួកមន្ត្រីគយនៅតំបន់ព្រំដែនច្រកបាវិត ខេត្តស្វាយរៀង សុំមិនបញ្ចេញឈ្មោះ បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា ស្បែកជើងសង្រែក ដែលមានបោះពុម្ពរូបអង្គរវត្តនៅបាតស្បែកជើង បានផលិតចេញពីប្រទេសវៀតណាម ។ ដោយមន្ត្រីគយនោះនិយាយថា ពួកគេមានបំណង គឺផលិតឡើង ដើម្បីទាក់ទាញអតិថិជនប្រទេសឱ្យទិញពាក់ និងបំណងមើលងាយមើលថោកជាតិខ្មែរដោយចេតនា ដែលគួរអត់ឱនបាន ។

អ្នកសង្កេតការណ៍នយោបាយកម្ពុជា មើលឃើញថា ឥទ្ធិពលយួន នៅតែបន្តគ្របដណ្តប់ផ្នែកនយោបាយមកលើកម្ពុជា ទាំងនយោបាយដឹកនាំ សេដ្ឋកិច្ច និងវប្បធម៌ បំណងផ្លូវអាក្រក់កំទេចជាតិខ្មែរឱ្យរលត់រលាយ ។

គេពុំទាន់ឃើញមានប្រតិកម្មណាមួយនៅឡើយទេ ពីរាជរដ្ឋាភិបាលកម្ពុជា ដែលខ្មែរប៉ុស្តិ៍បានព្យាយាមទូរស័ព្ទជាច្រើនសារ ដើម្បីសុំការបកស្រាយពីអ្នកនាំពាក្យរាជរដ្ឋាភិបាលលោក ខៀវ កញ្ញារិទ្ធ ប៉ុន្តែ ទូរស័ព្ទរបស់លោកត្រូវរោទិ៍គ្មានមនុស្សលើក ។

គេនៅចាំបានថា កាលពីខែតុលា ឆ្នាំ២០០៧ មានក្រុមហ៊ុនលក់កាតទូរស័ព្ទរបស់យួន នៅប្រទេសបារាំង បានគេចយករូបប្រាសាទអង្គរ ដាក់លេខ កាតទូរស័ព្ទរបស់គេក្នុងការធ្វើជំនួញ ។ និងជារឿយៗក៏មានក្រុមហ៊ុនកប៉ាល់របស់ជនជាតិកូរ៉េ ក៏ត្រូវបានយកទង់ជាតិខ្មែរ មានរូបអង្គរវត្តដោតលើកប៉ាល់ពួកគេបំផ្លែងការរកស៊ីក្នុងផ្លូវងងិត ។

ប្រាសាទអង្គរវត្ត ជានិមិត្តរូបជាតិ ដែលពិភពលោកស្គាល់ថា ជាប្រទេសកម្ពុជា ដោយមនុស្សម្នាពាសពេញសកលលោក បានចាប់យកតំបន់អច្ឆរិយៈអង្គរវត្តនេះ ធ្វើជាទីកន្លែងទេសចរកំសាន្ត និងស្នាក់នៅ ដែលស្ថិតិបង្ហាញពីចំនួនភ្ញៀវកើនដល់ជិត៣លាននាក់ ក្នុងចំណូលថវិកានាំចូលកម្ពុជាចំនួន១៤០០លានដុល្លារ កាលពីឆ្នាំ២០០៧ ។



LENG BEAUTY SALON



ហាងកាត់សក់-សំអាងការ

2224 E. ANAHEIM STREET • LONG BEACH, CA 90804
(562) 434-9621

មានជាងចំណានៗដែលមានការពិសោធន៍ជាច្រើនឆ្នាំជាមួយជំនាញកាត់សក់, អ៊ុតសក់ សម្រាប់មនុស្សគ្រប់វ័យ បុរស-ស្ត្រី ។

ហាងយើងខ្ញុំក៏មានទទួលតែងការក្នុងពិធីរៀបអាពាហ៍ពិពាហ៍តាមម៉ូតស៊ីវិល័យទាន់សម័យនិយម់ឬបែបប្រពៃណីបូរាណ ។

-ទទួលសាក់ចិញ្ចើម និងគូរភ្នែក

សូមអញ្ជើញ ដោយមេត្រីភាព!

ហាងយើងខ្ញុំត្រូវការរកជាងលាបក្រចកម្នាក់ និងរកជាងអ៊ុតសក់ម្នាក់ !



## ជួបជាមួយគ្រូគុនដំបង....

វាលស្រែឆ្ងាយពីភូមិ ដើម្បីបង្រៀនដល់ក្មេងណាដែលចង់ចេះ ។

បើយើងបែរមកមើលពីលោក ជាតិ សាវឿត វិញ វាហាក់មិនគួរឱ្យជឿទាល់តែសោះ នៅពេលដែលមនុស្សម្នាក់នេះមានដល់សញ្ញាប័ត្របរិញ្ញាពីសាកលវិទ្យាល័យ Domingues ផ្នែកវិទ្យាសាស្ត្រនយោបាយមានការងារល្អធ្វើនៅក្នុងសហរដ្ឋអាមេរិក ហើយដែលយើងឆ្ងល់ដែរថា មានចំណេះផ្នែកនយោបាយជាអ្នកដឹកនាំ គួរតែត្រូវយកជីវិតទៅប្រឡូកលេងជាអ្នកនយោបាយជាមួយគណបក្សណាមួយនៅក្នុងរដ្ឋអាមេរិក ឬនៅឯប្រទេសកម្ពុជា ចុះហេតុអ្វីរូបគាត់ត្រូវផ្ទុយស្រលះពីការគិត ដោយបានឈប់ធ្វើការជាង៣ឆ្នាំទៅហើយ រស់ជាមួយប្រពន្ធដែលជារដ្ឋការ ធ្វើការនៅ Social Worker ដែលក្នុងបន្ទុកមានកូន៣នាក់ ដើម្បីស្រាវជ្រាវចងក្រងឯកសារក្បាច់គុនទៅវិញ ដោយគាត់បានបន្តសំដីថា "រស់ជាមនុស្សត្រូវធ្វើអ្វីដើម្បីជាតិ ទោះតិច ច្រើនក្តី វាជាការប្រសើរ មុននឹងលាចាកលោកយើងនេះទៅ" ។

* បើលោកអ្នក ឬកូនចៅរបស់លោកអ្នកគិតថា ជាការល្អសំរាប់ជីវិតលោកអ្នកក្នុងការចង់ចេះក្បាច់គុនដំបង ឬគិតថាចង់នាំគ្នារក្សានូវអ្វីដែលដូនតាយើងរក្សាទុក ដើម្បីរក្សាបន្តក្នុងនាមជាអ្នកជាតិនិយម ជាពូជខ្មែរអង្គរ សូមអញ្ជើញទៅសាកមើលការបង្រៀននៅមជ្ឈមណ្ឌល Homeland Cultural Center / Macarthur Park 1321E. Anaheim Street, Long Beah, CA 90813.

Free Lession, Learn Tae Kwon Do and Khmer Traditional Arts, Open to all ages, People, and group.

Operating Hours: Thursday 5 P.M - 6 P.M

: Friday 5 P.M - 6 P.M

សូមទាក់ទងទូរស័ព្ទលេខ: (562) 230-5731

(562) 234-4603

(562) 209-8187

## សហរដ្ឋអាមេរិក....

បេក្ខជនណា ដែលនឹងពូកែខាងកែរទម្រង់ សេដ្ឋកិច្ច ប្រទេសដែលមានដាំក្បាលចុះ តាំងពីសហរដ្ឋអាមេរិកសម្រេចវាយលុកប្រទេសអាហ្គានីស្ថាន និងប្រទេសអ៊ីរ៉ាក់មក ។ ចំណែកឯការដកទ័ពអាមេរិកចេញពីប្រទេសអ៊ីរ៉ាក់នោះ គឺរដ្ឋបាលលោក ជច ប៊ូស បានយល់ព្រមធ្វើតាមសភាអាមេរិកាំង ដឹកនាំដោយ គណបក្សប្រជាធិបតេយ្យរួចហើយ ។

សហគមន៍ខ្មែរភាគច្រើន ចូលចិត្តធ្វើការគាំទ្រដល់គណបក្សសាធារណរដ្ឋ ដោយគេយល់ថា នយោបាយក្រៅប្រទេសរបស់គណបក្សនេះ អាចជួយកម្ពុជាបាន ។ រីឯយុវជនដែលរៀនបានជ្រៅជ្រះ នៅអាមេរិកនេះវិញ ច្រើនចង់គាំទ្រគណបក្សប្រជាធិបតេយ្យ ដោយគេយល់ថា ពួកគេនឹងរស់នៅអាមេរិកនេះយូរ ដូច្នេះត្រូវការឱ្យរដ្ឋបាលជាតិគិតពីបញ្ហាក្នុងស្រុកឱ្យបានច្រើន ។

ស្ថានភាពលទ្ធផលសន្លឹកឆ្នោត រហូតមកដល់ថ្ងៃទី២០ ខែមករានេះ បារ៉ាក់ អូបាម៉ា អាចនឹងមានវាសនាជាបេក្ខជនប្រធានាធិបតីសំរាប់គណបក្សប្រជាធិបតេយ្យបាន ហើយក៏អាចនឹងក្លាយជាប្រធានាធិបតីស្បែកខ្មៅដំបូងគេបង្អស់នៅអាមេរិកទៀតផង ។ ក្នុងស្ថានភាពដូចគ្នានេះដែរ ហ៊ីឡារីគ្លីង តុន ក៏អាចជាប្រធានាធិបតីស្ត្រីដំបូងបង្អស់សំរាប់អាមេរិកដែរ ។

ចាប់ផ្តើមនៅថ្ងៃទី៣ ខែមករានេះទៅ រហូតដល់ថ្ងៃទី២៨ ខែមិថុនា ទើបបោះឆ្នោតជុំទី១ចប់សព្វគ្រប់ ៕

# តើ ហ៊ុន សែន ពិតជាបន្ត ដៃគូ...

ការងារ ក៏គួរនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើទៅភាគីជាដៃគូ ដើម្បីដាក់មនុស្សពីកូតារបស់ហ៊្វុនស៊ិនប៉ិចជំនួសវិញ ។ ប៉ុន្តែ ផ្ទុយទៅវិញ ហ៊ុន សែន បែរជាដាក់ជំនួសនូវមនុស្សក្នុងគណបក្សរបស់ខ្លួន ដែលមតិភាគច្រើន បានចោទសួរថា តើនេះមិនមែនជាចេតនាកម្មនយោបាយចង់បំបាត់ ឬដកខ្លួនក្នុងភាពជាដៃគូក្នុងរាជរដ្ឋាភិបាល ឬយ៉ាងណា ? ។

ពាក់ព័ន្ធទៅនឹងការដែលមន្ត្រីហ៊្វុនស៊ិនប៉ិចជាច្រើនបានចុះចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា ដែលពួកអស់ទាំងនោះសុទ្ធតែមានតំណែងល្អៗ ក្នុងរដ្ឋាភិបាលកម្ពុជា ត្រូវបានអ្នកវិភាគនយោបាយទស្សទាយថា ការចង់ ឬមិនចង់ត្រូវបង្ខំចិត្តចុះចូលជាមួយគណបក្សលោក ហ៊ុន សែន ព្រោះវាមានហេតុបច្ច័យពីរយ៉ាង ដែលទី១ គឺសំពាធផ្នែកក្នុងនយោបាយពីគណបក្សប្រជាជនកម្ពុជាដាក់កំណត់ បើមិនចូលរួមជាមនុស្សរបស់គេទេ នឹងត្រូវបានដកតំណែង និងទី២ ការមើលឃើញលាភសក្ការៈ និងតំណែងខ្ពង់ខ្ពស់ ដែលត្រូវតែប្រថុយតាមជម្រាលរអិលនៃនយោបាយរបស់ ហ៊ុន សែន សិនទៅ ព្រោះពួកគេដឹងថា ក្រោយពីការបោះឆ្នោតមានរដ្ឋាភិបាលអាណត្តិទី៤ ពួកអ្នកនយោបាយគោចរទាំងនោះបានដឹងខ្លួនឯងថាអស់ផ្លូវដើរហើយ ។

ចំពោះ ហ៊ុន សែន វិញ បានអំពាវនាវក្នុងន័យបង្កប់សំដីហាក់ដូចមិនជាក់លាក់ណាមួយថា ហ៊្វុនស៊ិនប៉ិចត្រូវខិតខំប្រឹងប្រែងដោយខ្លួនឯង ដើម្បីបានធ្វើជាដៃគូក្នុងរដ្ឋាភិបាលជាមួយគណបក្សប្រជាជនកម្ពុជាក្នុងអាណត្តិទី៤ទៀត ។

ខណៈដែលមានមន្ត្រីជាន់ខ្ពស់ហ៊្វុនស៊ិនប៉ិចមួយចំនួនបានមកចូលរួមជាមួយគណបក្សប្រជាជនកម្ពុជារបស់លោក ហើយត្រង់លទ្ធផលប៉ុណ្ណោះ យើងមិនទាន់ដឹងបាននោះទេ ត្រូវរងចាំក្រោយការរាប់សន្លឹកឆ្នោត ទើបអាចដឹងបាន ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា អ្នកដែលចាកចេញពីហ៊្វុនស៊ិនប៉ិច មកចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា នេះជាសិទ្ធិជ្រើសរើសខាងនយោបាយរបស់ពួកគេ ។ ដោយលោក ហ៊ុន សែន បានរិះគន់ចំពោះអ្នកដែលបានលើកឡើងថា អ្នកមកចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាថា អ្នកក្បត់បក្ស ខ្វះឧត្តមគតិលក់ឧត្តមគតិនោះ គឺជាការខុសឆ្គងមួយក្នុងដំណាក់កាលប្រជាធិបតេយ្យ និងសិទ្ធិរបស់ប្រជាពលរដ្ឋដែលមានសិទ្ធិជ្រើសរើសនូវគណបក្សនយោបាយដែលគេពេញចិត្ត ។

ឧបនាយករដ្ឋមន្ត្រីហ៊្វុនស៊ិនប៉ិច លឺ ឡាយស្រេង ធ្លាប់អះអាងថា បើហ៊្វុនស៊ិនប៉ិច គ្មានមួយកៅអីនោះ តើអ្នកណាគេល្ងង់នឹងឱ្យតំណែងយើងកាន់ ។ ប៉ុន្តែ ឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ ដែលជាអគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច បានអះអាងថា វាទំនងជាមិនអាចចូលរួមនៅក្នុងរដ្ឋាភិបាលក្នុងអាណត្តិទី៤ ដូចដែលហ៊្វុនស៊ិនប៉ិចធ្លាប់បានធ្វើជាដៃគូនៅក្នុងរដ្ឋាភិបាលចំរុះកាលពី បីអាណត្តិមុននោះតទៅទៀតទេ ។ ដោយសារតែវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលគណបក្សប្រជាជនកម្ពុជាគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតរដ្ឋាភិបាលតែឯងដោយមិនចាំបាច់មានវត្តមានហ៊្វុនស៊ិនប៉ិច ។

លោក សម រង្ស៊ី និងលោក ហ៊ុន សែន បានជួបគ្នា កាលពីឆ្នាំ២០០៦ ក្រោយពីបានចូលស្រុកវិញ បន្ទាប់ពីនិរទេសនយោបាយអស់រយៈពេល១ឆ្នាំ នៅក្រៅប្រទេសដោយអ្នកទាំងពីរសន្យានឹងកែប្រែរដ្ឋធម្មនុញ្ញ សម្រេចការតែងតាំងរដ្ឋាភិបាលអាណត្តិក្រោយដោយ ៥០+១ បញ្ចៀសបញ្ហាជាប់គាំងផ្នែកនយោបាយនោះ ។ ដែលបញ្ហានេះ គេមើលឃើញជាឱកាសល្អសំរាប់ ហ៊ុន សែន ដែលអាចកាន់អំណាចតែក្នុងរង្វង់បក្សរបស់គាត់តែមួយយ៉ាងស្រួល ។

ពួកអ្នកវិភាគប្រមើល័ថា គណបក្សហ៊្វុនស៊ិនប៉ិច មានវាសនានយោបាយមិនខុសពីគន្លងផ្លូវដូចគណបក្សលោកតា សឺន សាន ដែលបានបែកបាក់គ្នាជាមួយលោក អៀង មូលី ដែលទីបំផុតគណបក្សមួយនេះ ត្រូវគ្មានកៅអីសភានៅទីបញ្ចប់ ។

អតីតព្រះមហាក្សត្រសម្តេច សីហនុ ធ្លាប់មានព្រះរាជបន្ទូល កាលពីឆ្នាំ២០០៣ថា គណបក្សហ៊្វុនស៊ិនប៉ិច ដែលព្រះអង្គធ្លាប់ជាអតីតអ្នកស្ថាបនិកក្នុងជំរុំតស៊ូ នាទសវត្សរ៍ឆ្នាំ៨០ នឹងអាចរលាយបាត់នៅឆ្នាំ២០០៨នេះ ។

គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច បានបែកបាក់ផ្ទៃក្នុង រហូតកើតមានអង្គសមាជរបស់ខ្លួន ធ្វើការបណ្តេញព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ចេញពីព្រះប្រធានគណបក្សកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ដែលព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ចោទប្រកាន់ថា បានធ្វើរដ្ឋប្រហារបណ្តេញព្រះអង្គដោយខុសច្បាប់ដោយធ្វើឱ្យព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ សម្រេចព្រះទ័យបង្កើតនូវគណបក្សថ្មីមួយទៀត ដែលដាក់ព្រះនាមព្រះអង្គផ្ទាល់ កាលពីឆ្នាំ២០០៧ ។

គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិច ធ្លាប់បានឈ្នះឆ្នោតនាឆ្នាំ ១៩៩៣ ក្រោមការត្រួតត្រារបស់អ៊ុនតាក់ (UNTAC) ដោយមានការសម្បទានឱ្យដល់គណបក្សប្រជាជនកម្ពុជារបស់ក្រុម ជា ស៊ីម, ហេង សំរិន, ហ៊ុន សែន ធ្វើជាដៃគូជាមួយនៅពេលដែលក្រុមគណបក្សប្រជាជនកម្ពុជាត្រៀមខ្លួន បំរុងធ្វើវិទ្ធស្សនាបែបតំបន់អបគមន៍ខាងកើតទន្លេមេគង្គ ដើម្បីជាលេសចរចារក្នុងហេតុផលនយោបាយ ។

រហូតដល់កើតមានរាជរដ្ឋាភិបាលកម្ពុជាដែលមាននាយករដ្ឋមន្ត្រីដល់ទៅពីរនាក់ ដែលពិភពលោកមិនធ្លាប់មាន ។

នៅអាណត្តិបន្តបន្ទាប់ ក្នុងឆ្នាំ១៩៩៨ និងឆ្នាំ២០០៣ ហ៊្វុនស៊ិនប៉ិច បានចុះខ្សោយឥទ្ធិពលនយោបាយពីការគាំទ្ររបស់ប្រជារាស្ត្រ និងអ្នកសកម្មជននយោបាយរបស់ខ្លួន ដែលមិនពេញចិត្តនឹងទង្វើរបស់ថ្នាក់ដឹកនាំ ដែលបង្កបញ្ហាពុករលួយប្រកាន់បក្ខពួកក្នុងការតែងតាំងដឹកនាំនៃមុខតំណែងរដ្ឋាភិបាល និងការទាត់ចោលដោយមិនអើពើជាមួយអតីតក្រុមអ្នកតស៊ូ ។ ពិសេសបញ្ហាដកតំណែងលោក សម រង្ស៊ី ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ឆ្នាំ១៩៩៥ និងការបង្កើតគណបក្ស សម រង្ស៊ី រួមនឹងការដើរចេញពីក្រុមលោក ទន់ ចាយ, ដួង ខែម នាឆ្នាំ១៩៩៧ ទៀត កាន់តែធ្វើឱ្យហ៊្វុនស៊ិនប៉ិចទន់ខ្សោយថែមទៀត ពីការបំបែកកម្លាំងអ្នកគាំទ្រ ហើយដែលទីបញ្ចប់មានគណបក្សសិទ្ធិ មនុស្ស គឹម សុខា មួយថ្មីមកទៀត វារិតតែធ្វើឱ្យគណបក្សហ៊្វុនស៊ិនប៉ិចកាន់តែលំបាកបន្ថែមទៅទៀត ក្នុងការប្រឹងប្រែងរបស់ខ្លួន ស្វែងរកសម្លេងរាស្ត្រគាំទ្រ នៅខណៈដែលផ្ទៃក្នុងបក្សរាជានិយមមួយនេះ កំពុងតែមានបញ្ហា ។

ក្រុមអ្នកវិភាគសង្កត់សំដីថា បើគ្មានការចូលរួមគណបក្សទាំងបួនឱ្យជួបជុំគ្នាវិញតែមួយទេ គឺគ្មានផ្លូវណាដែលថា យកឈ្នះគណបក្ស ហ៊ុន សែន ដែលកំពុងតែមានអំណាចសព្វថ្ងៃនេះបានទេ ។

ប៉ុន្តែការឈ្នះ ឬចាញ់ វាមិនសំខាន់ថា គណបក្សនយោបាយណាមួយនោះទេ ពោលគឺអ្វីដែលសំខាន់នូវត្រង់ថា គណបក្សណាឈ្នះឆ្នោតត្រូវមានឆន្ទៈនយោបាយដឹកនាំតាមបែបបទរដ្ឋាភិបាលសាធារណៈ ក្នុងប្រព័ន្ធប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពោលគឺគ្រប់គ្រងអំណាចទាំងបីឱ្យមានភាពដាច់ពីគ្នាវាង និតិបញ្ញត្តិ និតិប្រតិបត្តិ និងនិតិតុលាការ ដែលមិនចេញពីអំណាចបុគ្គលតែមួយ គឺជាការប្រាថ្នាចង់បានរបស់ប្រជារាស្ត្រជាម្ចាស់ឆ្នោត ។ ព្រោះប្រធានបទសំរាប់កម្ពុជាមានច្រើនណាស់ ដែលរាជរដ្ឋាភិបាលត្រូវប្រឈមមុខដោះស្រាយ ដើម្បីវាសនាជាតិខ្លួន ដែលបន្ទុកបញ្ហានោះមានអំពើពុករលួយការរំលោភបំពានដីធ្លី បញ្ហាជនអន្តោប្រវេសន៍ ការកាប់បំផ្លាញព្រៃឈើ និងភាពក្រីក្ររបស់ប្រជាជនដែលកាន់តែក្រៗទៅគ្មានដីធ្វើស្រែចំការ ហើយអ្នកដែលមានឥទ្ធិពលអំណាចបុណ្យស័ក្តិ និងលុយកាន់តែមានឡើងៗ រំលោភបំពានអ្នកក្រីក្រ ។ ដែលចំណោទទាំងប៉ុន្មាននេះ គេពិតជាសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៤ ក្រោយការបោះឆ្នោតខែកក្កដាឆ្នាំ២០០៨ នឹងដាក់តុមូលពិភាក្សាដោះស្រាយក្នុងកំណែទម្រង់នយោបាយរដ្ឋាភិបាលថ្មី (Reform of Good Government) ៕

# ជីវិតអ្នកចំរៀងខ្មែរម្នាក់...

អ្នកផ្តល់ភាពសប្បាយត្រូវបានគេគោរព ដូចជាព្រះ នៅក្នុងប្រទេសកម្ពុជាដោយសារក្រមសីលធមិតឹងតែង ព្រមជាមួយនឹងច្បាប់ទម្លាប់នានាផងនោះ បានធ្វើអោយការបញ្ចេញមតិមានតិចតួច ។

ហេតុនេះ នៅពេលដែល ដារ៉ានី មាន ឱកាសបានមក សិក្សានៅសហរដ្ឋអាមេរិក នាងមានសេចក្តីរំភើប ត្រេកអរជាខ្លាំង។ នាងមកដល់សហរដ្ឋអាមេរិក ក្នុងកំឡុងឆ្នាំ១៩៩៩ ដោយគិតថា នឹងបានចូលរៀន ហើយមានការងារធ្វើដូចមនុស្សភាគច្រើនដែរ ប៉ុន្តែក្តីស្រឡាញ់ពេញចិត្តក្នុងជីវិតរបស់នាង គឺការច្រៀង ហើយវាក៏ជាសំណាងរបស់នាងដែរ ដែលនាងបានជួបជាមួយអ្នកជួយគាំទ្រជាជនជាតិខ្មែរខ្លះ ដែលបានលើកទឹកចិត្តអោយនាងឡើងសំដែងលើឆាក ។ ដារ៉ានី ព្រមជាមួយនឹងប្អូនស្រីរបស់នាងម្នាក់ទៀត គឺ ដារីយ៉ា បានចាប់យកការសំដែងពេញទំហឹងមែនទែនក្នុងឆ្នាំ ២០០៣ ។



ដារីយ៉ា និង ដារ៉ានី (បងប្អូនបង្កើត)

ចំណង់ចំណូលចិត្តខាងចំរៀងបានធ្វើអោយនាងមានលទ្ធភាព ធ្វើដំណើរក្នុងសហរដ្ឋអាមេរិក ដែលមានសហគមន៍ខ្មែររស់នៅច្រើន ។ ដំបូងឡើយឪពុកម្តាយរបស់នាងនៅប្រទេសកម្ពុជាជំទាស់ជាខ្លាំង ចំពោះរឿងនេះ តែក្រោយមកបានដឹងថាកូនស្រីរបស់ពួកគាត់បានធ្វើអោយមានការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់សហគមន៍ខ្មែរ ហើយពួកគេបានក្លាយជាអ្នកគាំទ្រយ៉ាងធំធេង ចំពោះកូនស្រីពួកគាត់ ។ សព្វថ្ងៃនេះ ដារ៉ានី មានហាងម៉ូដសំលៀងបំពាក់របស់នាងផ្ទាល់នៅទីក្រុងខ្មែរនៃក្រុងឡុងប៊ិច ។ ទៅអនាគតនាងមានបំណងបើកសាខាលក់រាយមួយទៀត នៅប្រទេសកម្ពុជា ។ សព្វថ្ងៃនេះ គេអាចឃើញ ដារ៉ានី ច្រៀងប្រចាំនៅភោជនីយដ្ឋាន La Lune ក្នុងក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រនីញ៉ា នៅរៀងរាល់ចុងសប្តាហ៍ ។ នៅពេលណាដែលមានឱកាសនាងនឹងធ្វើដំណើរទៅរដ្ឋផ្សេងៗទៀត ហើយប្រហែលជាទៅក្រៅប្រទេសផងដែរ ។

នេះជាឧទាហរណ៍ជាក់ស្តែងមួយ ដែលចង់បង្ហាញអំពីការខិតខំធ្វើការ និងការប្តេជ្ញា ចិត្ត ដែលអាចនាំទៅរកភាពជោគជ័យ និងជីវិតរីករាយ ។ ឥឡូវនេះ ដារ៉ានី កំពុងតែទទួលបានផលផ្លែ ដែលចេញពីការងាររបស់នាង ហើយនាងកំពុងរស់ក្នុងពិភពសុបិន្តនៃសហរដ្ឋអាមេរិក ៕

❋❋❋❋❋❋❋❋

SAMS BODY & PAINT (562) 489-2877 MECHANICAL

ហាងខ្មែរធ្វើតួ និងបាញ់ថ្នាំរថយន្ត

SAM'S AUTO BODY

CUSTOM COLLISION REPAIRS

COMPLETE AUTO PAINTING

RESTORATION INSURANCE WORK

FLAT BED TOWING AVAILABLE

BORIN

TEL: 562-489-2877

FAX: 562-489-0022

CEL: 562-577-8259

EXPERT FRAME & BODY WORK

1427 Long Beach Blvd., Unit A, Long Beach, CA 90813

ហាងយើងខ្ញុំ និងជួលរថយន្ត អោយជិះដោយមិនគិតថ្លៃ បើលោក អ្នកយករថយន្តមកធ្វើនៅកន្លែង យើងខ្ញុំ



## កុមារខ្មែរដង្ហោយរកការជួយ...

លក់ពលកម្ម ឬលក់ខ្លួនឱ្យជនបរទេស និងកុមាររាប់ពាន់នាក់ទៀតត្រូវឆ្លងដែនទៅកាន់ប្រទេសថៃ និងយួន ដើម្បីធ្វើការសុំទាន ។ រីឯកុមារដែលមិនទៅណាឆ្ងាយពីឪពុកម្តាយ ហើយមិនបានទៅសាលារៀន ត្រូវចូលព្រៃរុករកចំណីអាហារ ព្រៃ ជីកត្រពាំង ដំឡូង ក្តួច ក្តាម ខ្យង និងបរបាញ់ សត្វ ដើម្បីចិញ្ចឹមជីវភាពគ្រួសារ ហើយដែលការដើរផ្សងព្រេងក្នុងព្រៃប្រឹក្សានោះ មានកុមាររាប់រយនាក់បានស្លាប់ និងពិកាដោយសារជាន់មីន និងគ្រាប់មិនទាន់ផ្ទុះក្នុងមួយឆ្នាំៗ ដែលនេះគឺជាសោកនាដកម្មទុក្ខលើទុក្ខក្នុងជីវភាពគ្រួសារពួកគេដែលកំពុងតែទីទ័លក្រ ។

*** បើអ្នកចង់ជួយឧបត្ថម្ភក្នុងនាមខ្មែរជួយខ្មែរ... ស្រឡាញ់មាតុភូមិ និងផ្តល់ក្តីអាណិតអាសូរចំពោះជីវិតកុមារកម្ពុជា សូមមេត្តាចូលរួមវិភាគទានក្នុងកម្មវិធី** Special Invitaltion "Fundraising" **ដែលប្រារព្ធធ្វើនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោង ៧:00 PM នៅភោជនីយដ្ឋានឋានសួគ៌ថ្មី លោកអ្នកអាចទាក់ទងអ៊ុក ច័ន្ទដារ៉ា** (562) 428-8512 ៕

ឱសថស្ថានខ្មែរថ្ងៃនេះ

Today Pharmacy

2200 E. Anaheim St.#C Long Bach, CA 90804

Tel: (562) 438-2031 • Fax: (562) 438-2031

(2 Blocks East of Cherry Ave.)

Fast and Friendly Service

- Today Pharmacy គឺជាឱសថស្ថានបំរើការចែកចាយថ្នាំតាមវេជ្ជបញ្ជា ។
- ទទួលយកនៅ Medicare & Medical និង Insurance ។
- ដឹកជញ្ជូនថ្នាំផ្តល់ជូនឲ្យដល់គេហដ្ឋានដោយមិនគិតពីកំរៃផងដែរ ។

• FREE DELIVERY TODAY:

ថ្ងៃល្អរបស់លោកអ្នក សូមស្វាគមន៍!

# KING KONG
STUDIO & DIGITAL LAB
*Photography*

*"Capturing Moments..."*



*1617 E. Anaheim St. | Long Beach, CA 90813 | Tel.: (562) 591-2296*

*Hours: Monday - Sunday (9:30am - 6:00 pm)*

## Passport & Immigration Photo, Notary

ជាមួយហាងយើងខ្ញុំដែលមានបទពិសោធន៍ជាង ១៥ ឆ្នាំ មានបច្ចេកទេសខ្ពស់ និងទំនើបទាន់សម័យសំរាប់អស់លោកអ្នកដែលមានបំណងចង់ភ្ជាប់នូវរូបថតទុកជាអនុស្សាវរីយ៍សំរាប់មើលកំសាន្ត ។



*Wedding*
មានថតរូបពិធីមង្គលការ



*Glamour*
តុបតែងសម្ផស្សឱ្យកាន់តែប្រសើរ



*Family*
ថតរូបជាលក្ខណៈគ្រួសារ



*Children*
តុបតែងថតសំរាប់កុមារ



*Restoration*
កែលំអរូបថតចាស់ៗឱ្យស្អាតឡើងវិញ

ថតភ្លាមយកភ្លាមត្រឹមតែ៥នាទី

*In 5mn*



●ទទួលផ្ញើរលិខិតឯកសារតាម E-mail

●មានធ្វើ Flyer , Name Card

សូមអញ្ជើញដោយមេត្រីភាព !

@ *www.kksphotostudio.com*

មានថតរូបសំរាប់ធ្វើលិខិតឆ្លងដែន ,ទិដ្ឋាការ និងកិច្ចការអន្តោប្រវេសន៍





**King Kong**

ជាទីសម្រស់ដ៏ល្អប្រណិត គ្មានពីរបស់អស់លោកអ្នក!



*Photography | Videography | Film | Digital Media | Frames*

មានម៉ាស៊ីនថតសន្លឹក ម៉ាស៊ីនថតវីដេអូ ផ្តិតរូបថត ផ្តិតរូបដោយកុំព្យូទ័រ Digital បែបទំនើប បញ្ចូន Frame ស៊ុមរូបថត

*KKS*

*1617 E. Anaheim St. | Long Beach, CA 90813 | Tel.: (562) 591-2296*

## THE FUSION ...

*forgotten"* (Phim page 49).

*Reflections of a Khmer Soul* can be purchased through many retailers:

1) Directly from the publisher www.wheatmark.com.
2) Through online bookstores like Amazon, Barnes and Noble or Borders.
3) autographed copy from www.khmerhut.com.
4) At local coffee shops in Long Beach: Portfoilo Coffee House and NuArt Café.

The book has already received rave reviews by many top academic scholars across the country. Even with the growing success of her book, the author has remained humble and even contributes a portion of book sales to charitable fundraisers.

On October 20, 2007 Navy sold and autographed copies of her book at a cultural event held at CSULB. The public event - *Cambodia 30 years after the Killing Fields* - was hosted by the Dr. Haing S. Ngor Foundation. Excerpts from Navy's book were read aloud. The audience, comprised of Khmer and non-Khmer- listened… captivated… contemplative. This book is highly recommended for audience of any ethnicity because it is ultimately a story about humanity. For more information please visit the author's personal website www.navyphim.com.


ហាងលក់គ្រឿងបន្លាស់រថយន្ត
LONG BEACH AUTO PARTS
Imports & Domestics
Free Delivery



សំរាប់អតិថិ-
ជនដែលមាន
បំណងផ្លាស់ប្តូរ
គ្រឿងបន្លាស់រថយន្ត
សូមអញ្ជើញមកជាវគ្រឿង
បន្លាស់ហាងយើងខ្ញុំដែលមាន
ច្រើនប្រភេទតាមតម្រូវការ
របស់អតិថិជន

1310B Stanley Ave
Long Beach, CA 90804 (562) 433-8090,(562) 433-8093



TOYOTA OF LONG BEACH
-ត្រូវការជ្រើសរើសអ្នកលក់ឡានចំនួន ៣នាក់ (Sales person) មិនថាប្រុស ឬស្រី ដែលជាជនជាតិខ្មែរ មានស្ទាត់ជំនាញភាសាខ្មែរ និងអង់គ្លេស ។
-មានទំនាក់ទំនងសាធារណៈល្អក្នុងទីផ្សារ និងមហាជននៃសហគមន៍ក្រុង Long Beah និងទីតំបន់ខ្មែរដទៃទៀត ។
-អ្នកលក់ឡាន (Sales Person) ត្រូវទទួលបានភាគរយក្នុងឡានមួយ ៣៥%(Commission) ។
-បើលោកអ្នកមានការចាប់អារម្មណ៍ចង់ធ្វើការជាមួយក្រុមហ៊ុនយើងខ្ញុំ សូមអញ្ជើញទាក់ទងនូវអាស័យដ្ឋានខាងក្រោម :
4401E. Pacific Coast Highway Long Beach, CA 90804
Phone: (562) 494-4444 /Fax: (562) 494-1350





វិមានមាស ភោជនីយដ្ឋាន និង រង្គសាល

1360 E , Anaheim St., Long Beach, CA 90813
Tel: (562) 591-7300 Fax: (562) 591-7331
Mon., Wed., Thu, 10AM- 10PM
Fri, Sat, Sun, 9 AM -2 AM (LIVE ! BAND )
Tuesday (Closed)



សូមអញ្ជើញភ្ញៀវសជាតិម្ហូប ខ្មែរ ថៃ នៅភោជនីយដ្ឋាន **វិមានមាស** ដែលបានបើកទ្វារបំរើអស់លោកអ្នក ចាប់តាំងពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នេះហើយ !!!




ចំណែកឯរង្គសាល **វិមានមាស** ក៏បានបើកទ្វារបំរើអស់លោកអ្នក រាំកំសាន្តជាមួយក្រុមតន្ត្រី **វិមានមាស** រៀងរាល់ចុងសប្តាហ៍ ចាប់ពីថ្ងៃ សុក្រ រហូតដល់ថ្ងៃ អាទិត្យ

ភោជនីយដ្ឋាន និង រង្គសាល វិមានមាស មាន ទទួលសំអាងការ ទទួលរៀបអាពាហ៍ពិពាហ៍ បុណ្យខួបកំណើត និង ពិធីជប់លៀងផ្សេងៗ...

# LAW OFFICES OF BOROTH CHAY

# ការិយាល័យមេធាវី



▸មេធាវីខ្មែរពូកែក្តីក្តាំនូវករណីគ្រោះថ្នាក់ចរាចររថយន្ត
◆អន្តោប្រវេសន៍ (ធានាប្តីប្រពន្ធ, គូដណ្តឹង, បងប្អូន) ◆ច្បាប់គ្រួសារ
◆បណ្តឹងលែងលះ ◆ប្រាក់ចិញ្ចឹមកូន ◆ឧក្រិដ្ឋកម្ម ◆រដ្ឋប្បវេណី ◆ច្បាប់ក្ស័យធន
▸បើមិនឈ្នះក្តី គឺមិនគិតកម្រៃ .ពិគ្រោះយោបល់ ឬពិភាក្សាមិនគិតថ្លៃ
▸ករណីប្តឹងផ្តល់នឹងផ្តល់ចម្លើយជូនលោកអ្នក ថាតើបណ្តឹងរបស់លោកអ្នក
មានសង្ឃឹមឈ្នះឬយ៉ាងណា? តើគួរធ្វើការប្តឹងផ្តល់ដែរឬទេ? ។



**Up to 50% of Settlement to Clients**

▸Bankruptcy ▸Family Law ▸Dissolution of Marriage
▸Child and Spousal Support ▸Immigration
▸Family Sponsor Petition ▸Auto Accident
▸Low Contingency ▸No Recovery ▸No Fee.

**Personal Injury:**

Auto Accident Free Consultation
How strong is your case?
Should you file a claim?

We'll answer your questions!

**Other Legal Representations:**

Family Law: Dissolution of Marriage,
Spousal and Child Support Bankruptcy
Immigration Law: Family sponsored petition

**5199E. Pacific Coast HWY, Ste. 206, Long Beach, CA 90 804**
**Tel: (562) 961-0142 .(562) 453-5898**

# M.L.K MARKET





▸ ហាងខ្មែរលក់ទំនិញមានសំលៀកបំពាក់ជាឯកសណ្ឋានសិស្ស (Uniform), រឿងកុនថៃ, ចិន, កូរ៉េ ផ្នែកមនោសញ្ចេតនា បាញ់ប្រហារ កាប់ចាក់ និងក្បាច់គុណបុរាណ កំពុងចេញលក់ថ្មីៗមានបកប្រែជាភាសាខ្មែរ ។
▸ ហាងខ្មែរ M.L.K ក៏មានកន្លែងលក់ទឹកផងដែរ ។
▸ ហាងយើងខ្ញុំក៏មានលក់ដូរនូវសំលៀកបំពាក់ជាច្រើនផ្នែកទៀត ទាំងសំភារៈផ្ទះបាយ, សំភារៈដំណេក, សំភារៈបន្ទប់ទឹក និងឧបភោគគ្រឿងទេស, ភេសជ្ជៈជាដើម ។









សូមអញ្ជើញជាមួយហាងថ្មីយើងខ្ញុំដោយរីករាយ

**1821 M.L.K.JR Ave, Long Beach, CA 90806**
**Tel: (562) 591-4295**


CATHAY PACIFIC
សូមស្វាគមន៍...
CATHAY PACIFIC
Cathay Pacific
ជានិច្ចកាលតែងតែនាំមកនូវ
ភាពងាយស្រួល និងទំនើប...!
LEAP Live Back Seat - features Office Chair technology to Provide active postural support.
9" Personal TV featuring "Audio Video On Demand"
Fixed seat back design-creates a fixed living space that no longer interrupts the space behind when a passenger reclines
DISCOVERY
Literture pocket relocated below the seat cushion to creat more room .
ក្រុមហ៊ុន CATHAY PACIFIC AIRWAYS បានផ្តើមការហោះហើរ បំរើអតិថិជន ចាប់ពីខែ ធ្នូ ឆ្នាំ២០០៧ នេះទៅហើយ នូវប្រភេទយន្តហោះ BOEING ថ្មីដ៏ធំបំផុត ដែលរចនាតុបតែងឡើងយ៉ាងល្អប្រណិតក្នុងបច្ចេកទេសខ្ពស់ និងជាសុខភាពល្អ កៅអីធំទូលាយ ងាយស្រួលអង្គុយ និងចេញចូល ទូរទស្សន៍ផ្ទាល់ខ្លួន មានទំហំធំរហូតដល់៩អ៊ីង សំរាប់ថ្នាក់ជិះផ្នែក ECONOMY ។ ក្រុមហ៊ុន CATHAY PACIFIC ហោះហើរពាដើងក្នុងមួយថ្ងៃ ពី LOS ANGELES ទៅ HONG KONG ។ពី HONG KONG ទៅ PHNOM PENH រៀងរាល់ថ្ងៃ (រយៈពេលហោះហើរតែ ២:៣០ នាទី តែប៉ុណ្ណោះ )។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានលើយន្តហោះមានជាភាសាខ្មែរផងដែរ ។


PHNOM PENH express
PHNOM PENH EXPRESS
ក្រុមហ៊ុនទទួលផ្ញើរប្រាក់ និងលក់សំបុត្រយន្តហោះ
Mon-Sat 9am-6pm
Sunday: 10am-5pm
ទទួលផ្ញើរប្រាក់ទៅកាន់ប្រទេសកម្ពុជា - វៀតណាម, មានលក់សំបុត្រយន្តហោះគ្រប់ក្រុមហ៊ុន,
ទៅគ្រប់ប្រទេស, លក់កាតទូរស័ព្ទគ្រប់ម៉ាក និងទទួលបង់វិក័យប័ត្រនានា ។ បំរើអតិថិជន៧ថ្ងៃក្នុងមួយសប្តាហ៍ ។
2140E. Anaheim St., Long Beach CA 90804 . Tel : (562) 434-3322, (562) 434-3760

C&B CROISSANTS
WHOLESALE ONLY

ORDER BY PHONE:
(562) 495-5713
(800) 974-3888
Cell: (562) 607-3258
Fax: (562) 495-7544

-ធានាគុណភាពទុកបាន ៣០ ថ្ងៃ
-ដឹកជញ្ជូនដោយមិនគិតថ្លៃ ពីថ្ងៃ ច័ន្ទ-សុក្រ
-ហាងយើងខ្ញុំមានលក់ដុំតែប៉ុណ្ណោះ
-អ្នកទិញត្រូវឱ្យដឹងមុន ១ថ្ងៃ

FREE DELIVERY
We guarantee our products up to 30 days. Order must be made 1 day in advance.
WHOLE SALE ONLY

# ហាងខ្មែរផលិតនំ
# ក្រូសង់



| Item | Net Wt Each | Packaging | Price/Package |
|---|---|---|---|
| Butter Croissant | 4.50 oz | 50 | $18.00 |
| Triangle Croissant | 5.00 oz | 50 | $18.00 |
| Square Croissant | 5.00 oz | 50 | $18.00 |
| Cream Cheese Croissant | 6.00 oz | 50 | $23.00 |
| Blueberry Cream Cheese Croissant | 6.oo oz | 50 | $23.00 |
| Strawberry Cream Cheese Croissant | 6.00 oz | 50 | $23.00 |
| Raisin Cinnamon Croissant | 6.00 oz | 50 | $23.00 |
| Raisin Custard Croissant | 6.00 oz | 50 | $23.00 |
| Apple Croissant | 6.00 oz | 50 | $23.00 |
| Chocolate Croissant | 6.00 oz | 50 | $23.00 |
| Chocotate Cream Cheese Croissant | 6.00 oz | 50 | $23.00 |
| Pineapple Cream Cheese Croissant | 6.00 oz | 50 | $23.00 |

1339 W. Gaylord Street• Long Beach, CA 90813




# ផ្ញើប្រាក់ទៅកាន់ខេត្តណាមួយនៅកម្ពុជា តាមរយៈ Western Union

## ជាមួយថ្លៃ* សេវាកម្មផ្ញើប្រាក់ទាប $11.99 ដុល្លារ

សម្រាប់ការផ្ញើប្រាក់ទៅកាន់ខេត្តក្រុង** ដែលបានជ្រើសរើសក្នុងចំនួនតិចជាង 500 ដុល្លារ

## ជាទូទៅប្រាក់អាចទទួលបានតែប៉ុន្មាននាទី*** ប៉ុណ្ណោះ

✓ ថ្លៃ*សេវាកម្មផ្ញើប្រាក់មិនមានការប្រែប្រួលទៅតាមទីកន្លែងរបស់ភ្នាក់ងារទទួលប្រាក់ឡើយ
✓ មានភ្នាក់ងារផ្ទេរប្រាក់ជាង 100 កន្លែងនៅ 24 ខេត្តក្រុងទូទាំងប្រទេសកម្ពុជា
✓ មិនចាំបាច់មានគណនីនៅធនាគារទាំងអ្នកផ្ញើ និងអ្នកទទួល
✓ មិនមានការគិតថ្លៃសេវាកម្មផ្ទេរប្រាក់ពីអ្នកទទួលឡើយ

**WESTERN UNION**

សេវាកម្មផ្ទេរប្រាក់ទូទាំងពិភពលោក រហ័សទាន់ចិត្ត និងគួរឲ្យទុកចិត្ត

**សូមទាក់ទងទូរស័ព្ទ 1-800-325-6000**

ភ្នាក់ងារផ្ទេរប្រាក់នៅកម្ពុជាដែលទទួលបានការអនុញ្ញាតពី Western Union: ACLEDA Bank Plc. CAB BANK SBC Bank

| | | | | |
|---|---|---|---|---|
| **NHA THUOC THIEN NHIEN**<br>1299 E. ANAHEIM ST<br>LONG BEACH, CA 90813<br>TEL: 562-218-2328 | **MONEY MART #0772**<br>1001 E. PACIFIC COAST HWY<br>LONG BEACH, CA 90806<br>TEL: 562-599-0991 | **MONEY MART #0767**<br>2375 LONG BEACH BLVD<br>LONG BEACH, CA 90806<br>TEL: 562-427-0253 | **CONTINENTAL CURRENCY #704**<br>3106 SAN GABRIEL BLVD<br>ROSEMEAD, CA 91770<br>TEL: 626-280-0380 | **TOPANGA CHECK CASHING**<br>7239 TOPANGA CANYON BLVD<br>CANOGA PARK, CA 91303<br>TEL: 818-594-0057 |
| **CONTINENTAL CURRENCY #408**<br>1301 LONG BEACH BLVD<br>LONG BEACH, CA 90813<br>TEL: 562-599-1550 | **ANTOJITOS LATINOS LIQUOR**<br>25381 ALICIA PKWY STE N<br>LAGUNA HILLS, CA 92653<br>TEL: 949-215-9708 | **NADERS MARKET**<br>25227 REDLANDS BLVD # I<br>LOMA LINDA, CA 92354<br>TEL: 909-796-1660 | **CONTINENTAL CURRENCY #413**<br>237 LONG BEACH BLVD<br>LONG BEACH, CA 90802<br>TEL: 562-432-5883 | **SIAM MARKET**<br>2505 E. ANAHEIM ST<br>LONG BEACH, CA 90802<br>TEL: 562-607-8970 |

*សម្រាប់ការផ្ទេរប្រាក់ដុល្លារអាមេរិចប៉ុណ្ណោះ។

**ថ្លៃសេវាកម្មផ្ញើប្រាក់នេះមានសុពលភាពចាប់ពីថ្ងៃទី 22 ខែ តុលា ឆ្នាំ 2007 នេះនៅតាមបណ្តាភ្នាក់ងារនានាដែលបានចូលរួមក្នុងកម្មវិធីរបស់ខ្លួននៅតំបន់ប្រជុំជន Los Angeles និង Philadelphia ។ Western Union សូមរក្សាសិទ្ធិក្នុងការកែប្រែដោយមិនចាំបាច់ជូនដំណឹងជាមុន។ ថ្លៃសេវាកម្មផ្ញើប្រាក់អាចត្រូវបានគិតច្រើនជាងនេះសម្រាប់ការផ្ញើប្រាក់តាមរយៈទូរស័ព្ទ និង តាមរយៈគេហទំព័រ www.westernunion.com ។

***រយៈពេលនៃការទទួលប្រាក់អាស្រ័យទៅលើកត្តាមួយចំនួននៃសេវាកម្មរួមទាំងម៉ោងធ្វើការ និងទីតាំងរបស់ទីភ្នាក់ងារផ្ទេរប្រាក់ព្រមទាំងភាពខុសគ្នារវាងម៉ោងនៅក្នុងតំបន់និមួយៗផងដែរ។ពិនិត្យមើលកត្តាកំណត់ និងល័ក្ខខ័ណ្ឌនានានៅក្នុងបែបបទ "ផ្ញើប្រាក់"។

©2007 Western Union Holdings, Inc. All Rights Reserved.


ASIAN PACIFIC INTL TRAVEL
ក្រុមហ៊ុនលក់សំបុត្រយន្តហោះ
មានលក់សំបុត្រគ្រប់ក្រុមហ៊ុនទៅ
កម្ពុជាដូចជា:
-Eva Airways
-China Airlines
-Singapore Airlines
-Thai Airways
-Malaysia Airlines
-Cathay Pacific
-Korea Airlines
-Asiana Airlines
*មានលក់សំបុត្រទៅប្រទេសផ្សេងៗទៀត ដូចជា: អឺរ៉ុប
*មានលក់សំបុត្រក្នុងប្រទេស USA
*មានលក់សំបុត្រយន្តហោះពីភ្នំពេញមក USA
កន្លែងនាងខ្ញុំមានប្រថាប់ត្រា
Notary Public Phone Card
Buy 4 get 1 free
$ 890 Tax included
តម្លៃពិសេស,អ្នកទិញ
សំបុត្រឥឡូវរក្សាទុក
រហូតដល់ខែ ឧសភា,
( May ) 08
ទទួលរៀបចំធ្វើ
Reentry , Permit , Urgent ,
ធានាប្ដីប្រពន្ធ,គូដណ្ដឹង,ក្រុមគ្រួសារ
សូមលោកអ្នកអញ្ជើញមកដោយមេត្រី
Prepaid - Phone Cards
Toll Free 1-800- 359 -6698
CAL -STATE
Realty & Leading
Real Estate *Home Loans
*Residential * Commercial
You will get the best deal
Magaret (LiLy) Chung
Realtor
Sell your home at 3,5%
Buy your home at 1 % Rebate
ធ្វើការដោយស្មោះត្រង់និងយកចិត្តទុកដាក់ជានិច្ច
1065 E. Anaheim Street.
Long Beach CA 90813
Tel: (562) 599 - 5464
Fax : (562) 599-5604
Tony´s Cell : (562) 537-3546
LiLy´s Cell : (562) 682-6588
4510 E. Pacific Coast Hwy,.
Ste.540 Long Beach, CA 90804
Tel: (562) 599-5464
Cell: (562) 682-6588
Fax: (562) 599-5604
Email : margaretchung@charter.net

WINSTAR CAPITAL

A Residential Mortgage Lending
License: # 01834778

100% CONFORMING
SISA AVAILABLE

WANTED: LOAN OFFICER AND Sr. LOAN OFFICER!!!

We're looking for:

- Motivated and career minded individual to join our sales team
- Seasoned Loan Officers and Senior Loan Officers
- Opportunity to build your team and manage your own branch
- We provide leads and referrals
- Generous commission splits
- We provide friendly, supportive & beautiful working environment
- Khmer speaking preferred

For confidential interview, please call Dan at:
(714) 594 - 5131

REAL ESTATE AGENTS & BROKERS COOPS

- Have an LO assigned to your office
- Coops Marketing plan
- Programs to boost your New Year 2008
- 100% Conforming Full Doc
- Jumbo Loan
- Hard Money

For more info, contact our sales team:
(714) 594 – 5135

17150 Newhope Street, Suite 503, Fountain Valley, CA 92708





Quality
Assured
Collision Center

"We do what's right to ensure your vehicle gets back to pre - accident condition"

1427 long beach , Blvd , Suite B
Long Beach , California , 90813
T : 562 599 0766 , F : 562 599 6504
QACollison@yahoo.com





" Mission Statement "

To Provide the highest quality of workmanship in reasonable time , while building a lifetime relationship with our customers

ធ្វើតួ និង បាញ់ថ្នាំឡាន
ជាមួយជាងចំណានៗ មានបទពិសោធន៍ខ្ពស់
ធ្វើឱ្យលោកអ្នកមិនខកបំណងឡើយ !











" Services Offered "

- Fast repairs with State-of-the-art equipment .
- Lifetime warranty on body and paint .
- Free estimates .
- Shuttle service .
- Free loaner vehicles , up 7 days .
- Free towing with vehicle repairs .
- I-CAR Free certified technicians .
- costomer Friendly staff .
- Waiting room with wireless internet .
- Computerized framer measurement , print put .
- Expert color mach .
- Auto mechanic on staff .
- 25 working boys .
- 65,000 square feet facility .
- We work with all insurance companies .

STATE -OF-THE-ART Equipment

- 2 chief EZ line 3 post frame machine .
- Garmat downdraft beated spray booth .
- PPG paint mixing room .
- Robinair air condition system reclaim ,evacuate and recharge equipment .
- CCC pathways estimating software .




# THE FUSION GENERATION:

**Long Beach artists born during the Killing Fields share their lives through music and literature.**

**by Tiara Delgado for the Khmer Post**

Born during the Killing Fields... with childhood memories of Thai refugee camps. They are the fusion generation. A fusion of two cultures. They are the middle generation of Khmer-Americans now in their late-20's to early 30's. Unlike older siblings who have extensive memories of Cambodia before and during the genocide, the fusion generation has limited or no memory of Cambodia. Unlike younger siblings born into peace and privilege, the fusion generation struggled with their parents to survive as refugees in their new American society.

Two young Long Beach artists from the fusion generation have chosen to share their lives with the world. One artist through music. One artist through literature. Both have incredible tales to tell. Their messages connect not only with Khmer communities but will resonate with audiences worldwide.

**PRACH LY - Rap Artist - Dalama 3: Memoirs of an Invisible War**

Prach Ly was born in 1979 at the end of the Killing Fields. His family made their way across landmine infested jungles to a refugee camp at the Thai border. After being sponsored to the US he struggled to survive the mean streets of Long Beach,


PRACH LY with Cambodian Students


PRACH LY

